# សេចក្តីផ្តើម

ការវិវត្តន៍ និងតំរូវការរបស់មនុស្សធ្វើអោយសង្គមមានការរីកចំរើន។ ការរីកចំរើនខាងផ្នែកប្រាជ្ញាស្មារតី និងរូបរាងកាយធ្វើអោយមនុស្សបង្កើតនូវរបបផ្សេងៗ និងទប់ស្កាត់នូវបាតុភូតធម្មជាតិទាំងឡាយ។ មនុស្សពីដំបូង គេធ្វើការផ្លាស់ប្តូរគ្នាទៅវិញទៅមក នេះគឺជាកំណើតដំបូងនៃពាណិជ្ជកម្ម។ការវិវត្តន៍ជាដំណាក់កាលធ្វើអោយមានការ បែកគំនិត អភិវឌ្ឍន៍ធ្វើពាណិជ្ជកម្មពីភូមិមួយទៅភូមិមួយ ពីតំបន់មួយទៅតំបន់មួយ រហូតដល់មានការធ្វើពាណិជ្ជកម្ម ឆ្លងទ្វីប។ នេះជាហេតុធ្វើអោយមានទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិ។ ដូច្នេះហើយបន្ទាប់ពីសង្គ្រាមលោកលើកទី ២ ប្រទេសជាច្រើនបានខិតខំអនុវត្តជាបន្តបន្ទាប់នូវវិធានសំរាប់គ្រប់គ្រងទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិ។ គេឃើញមាន អង្គការអង្គការពិភពលោកមួយថ្មីបើប្រៀបជាមួយអង្គការផ្សេងៗ គឺ អង្គការពាណិជ្ជកម្មពិភពលោក WTO ។

ស្របពេលជាមួយគ្នានិងការវិវត្តន៍នេះ ប្រទេសកម្ពុជាមានការវិវត្តន៍គួរអោយកត់សំគាល់ នៅក្នុងការរៀបចំ របបពាណិជ្ជកម្មទំនើបមួយ។ ក្នុងអំឡុងឆ្នាំ ១៩៦០ ប្រទេសកម្ពុជា ជាប្រទេសនាំចេញផលិតផលកសិកម្ម ជាពិសេសគឺ អង្ករ កៅស៊ូ និងពោត ហើយតុល្យភាពនៃការទូទាត់ក៏មានស្ថេរភាពដែរ។ ក៏ប៉ុន្តែចាប់តាំងពីឆ្នាំ ១៩៧០ មកប្រទេស កម្ពុជា បានផ្ទុះសង្គ្រាមឡើងទូទាំងប្រទេស ដែលជាកត្តាធ្វើអោយពាណិជ្ជកម្មក្រៅប្រទេសធ្លាក់ចុះស្ទើរតែទាំងស្រុង។ ប្រទេសកម្ពុជាបានឆ្លងកាត់នូវទុក្ខវេទនា ហើយក៏បានងើបឡើងជាថ្មីក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ ១៩៧៩។ ប៉ុន្តែ ប្រទេសកម្ពុជាត្រូវស្តារប្រទេសឡើងវិញទាំងបាទដៃទទេ និងស្ថិតនៅក្រោមគំនាបសេដ្ឋកិច្ចពីអង្គការសហប្រជាជាតិ រហូតដល់ឆ្នាំ១៩៩៣។ នេះជាពេលដែលប្រទេសកម្ពុជាមានឈ្មោះបោះសំលេងជាថ្មីលើឆាកអន្តរជាតិ។ ទទឹមនឹងនេះ ប្រទេសកម្ពុជា ត្រូវធ្វើការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិនឹងគ្រប់វិស័យ និងរកទីផ្សារដើម្បីនាំចេញផលិតផលក្នុងស្រុកទៅ កាន់ទីផ្សារបរទេស និងស្វែងរកអ្នកវិនិយោគទុន។ ការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក WTO គឺជា មធ្យោបាយមួយយ៉ាងសំខាន់សំរាប់កម្ពុជា។ ហេតុនេះទើបកម្ពុជាបានដាក់ពាក្យសុំចូលជាសមាជិកអង្គការពាណិជ្ជកម្ម ពិភពលោក WTO នៅថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ១៩៩៤ ហើយនៅក្នុងខែ កញ្ញា ឆ្នាំ ២០០៣ រដ្ឋមន្ត្រីមកពីប្រទេសជាសមា ជិកចំនួន ១៤៧ របស់ WTO បានទទួលយកលក្ខខ័ណ្ឌនៃការចូលជាសមាជិក WTO របស់ព្រះរាជាណាចក្រកម្ពុជា។ រយះពេល ៩ ឆ្នាំ គិតចាប់ពីការដាក់ពាក្យដំបូង កម្ពុជាបានអនុវត្តរាល់លក្ខខ័ណ្ឌទាំងអស់ ហើយសមាជិកភាពជាក់ស្តែង គ្រាន់តែតម្រូវអោយមានការផ្តល់សច្ចាប័នលើកិច្ចព្រមព្រេងនេះ ពីរដ្ឋសភាកម្ពុជាតែប៉ុណ្ណោះ។ កម្ពុជាបានទទួល សច្ចាប័ននេះ កាលពីថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០៤ ហើយសមាជិកភាពនៃប្រទេសកម្ពុជាក្នុង WTO បានចូលជាផ្លូវការ ក្នុងរយះពេល ៣០ ថ្ងៃក្រោយពីនោះ ពោលគឺនៅថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០០៤។

តើការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក WTO ត្រូវបំពេញលក្ខខ័ណ្ឌអ្វីខ្លះ? តើប្រទេសកម្ពុជា មានលក្ខណៈសម្បត្តិអ្វីខ្លះ ក្នុងការចូលជាសមាជិក ហើយការចូលជាសមាជិកមានគុណសម្បត្តិ និងគុណវិបត្តិអ្វីខ្លះ?

# ផ្នែកទី១ អង្គការពាណិជ្ជកម្មពិភពលោក WTO

## I. ប្រវត្តិសង្ខេបរបស់ WTO

### ក. និយមន័យ WTO

WTO គឺជាអង្គការ ដែលបន្តវេនពីកិច្ចព្រមព្រៀងពាណិជ្ជកម្មពីមុន ដែលហៅថា *កិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម (GATT)* ដែលគេបានបង្កើតឡើងនៅឆ្នាំ ១៩៤៨។ WTO មានសមាជិកច្រើនជាង GATT និងគ្របដណ្តប់លើកម្មវត្ថុច្រើនជាង។ ប៉ុន្តែ គឺ GATT នេះហើយ ដែលបានបង្កើតគោលការណ៍ពហុភាគីនៅក្នុងប្រព័ន្ធពាណិជ្ជកម្មនេះ។

WTO គឺជាស្ថាប័នមួយ និងជាសំណុំនៃវិធានទាំងឡាយ ដែលហៅថា *ច្បាប់ WTO* ។ អង្គការសំខាន់នៃច្បាប់របស់ WTO រួមមានកិច្ចព្រមព្រៀង និងសេចក្តីសម្រេចចិត្តជាង ៦០។ ទាំងអស់នេះត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ក្រុមប្រឹក្សា និងគណៈកម្មាធិការនានានៃទីស្នាក់ការកណ្តាលរបស់ WTO នៅទីក្រុង ហ្សឺណែវ ប្រទេស ស្វីស។ WTO គ្មានការិយាល័យនៅតាមប្រទេស ឬការិយាល័យប្រចាំតំបន់ទេ។ ករចរចារក្នុងទ្រង់ទ្រាយធំ ដូចជាកិច្ចប្រជុំនៅទីក្រុង ដូណា ( Dona រដ្ឋធានីប្រទេសកាតា ) ជាដើមតម្រូវអោយមានវេទិការចរចារពិសេសរបស់ខ្លួន។ សមាជិករបស់ WTO ថ្នាក់រដ្ឋមន្ត្រីជួបប្រជុំគ្នា យ៉ាងហោចណាស់ ពីរឆ្នាំម្តង។ ពេលក្រៅពីនេះ ប្រតិភូថ្នាក់ជាតិទាំងឡាយ ដែលតាមធម្មតាជាអ្នកការទូត និងជាមន្ត្រីពាណិជ្ជកម្មជាតិ ធ្វើការងារប្រចាំថ្ងៃ។

### ខ. ប្រវត្តិសង្ខេបរបស់ WTO

១៩៤៦-១៩៤៧ ការចរចារវាងប្រទេសចំនួន ៥០ ឧបត្ថម្ភគាំទ្រដោយអង្គការសហប្រជាជាតិ ដើម្បីបង្កើតអង្គការពាណិជ្ជកម្មអន្តរជាតិ (ITO) ដំណាលគ្នាជាមួយធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ។ សេចក្តីព្រាងមួយស្តីពី ITO ត្រូវបានបង្កើតឡើង។ ស្របជាមួយគ្នានេះដែរ ប្រទេសចំនួន ២៣ បានសំរេចចិត្តធ្វើការចរចារកាត់បន្ថយពន្ធនាំ ចូលក្នុងប្រទេសរបស់ខ្លួន និងដើម្បីអនុម័តសេចក្តីព្រាងវិធានពាណិជ្ជមួយចំនួនរបស់ ITO។ សម្បទានទាក់ទងនឹងពន្ធនាំចូល និងវិធានរួមគ្នាដែលហៅថា កិច្ចព្រមព្រៀងទូទៅ ស្តីពីពន្ធគយ និង ពាណិជ្ជកម្ម (GATT)។

១៩៤៨ ថ្ងៃទី ០១ ខែ មករា : GATT ចូលជាធរមានលើមូលដ្ឋានបណ្តោះអាសន្ន។ ក្នុងចំណោម សមាជិក ២៣ ប្រទេស កាលពីដំបូង មានប្រទេសចំនួន ១១ ជាប្រទេសកំពុងអភិវឌ្ឍខែមិនា សន្និសិទ្ធអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និងការផ្តល់ការងារ នៅទីក្រុង ឡាហាវ៉ាន នៃប្រទេសគុយបា

អនុម័តធម្មនុញ្ញរបស់ ITO ប៉ុន្តែធម្មនុញ្ញនោះចាំបាច់ត្រូវទទួលសច្ចាប័នពីអង្គការ នីតិបញ្ញត្តិថ្នាក់ជាតិ ។

១៩៥០ រដ្ឋាភិបាលសហរដ្ឋអាមេរិកប្រកាសថា ខ្លួននឹងមិនស្វែងរកការផ្តល់សច្ចាប័ន លើធម្មនុញ្ញ របស់ ITO ឡើយ ព្រោះមានការប្រឆាំងនៅក្នុងសភា ។ អាស្រ័យហេតុនេះ ITO ក៏ត្រូវបានគេរំលាយចោល ។

១៩៤៨-១៩៩៥ GATT នៅតែជាកិច្ចព្រមព្រៀង "បណ្តោះអាសន្ន" មួយដដែល ។

១៩៤៨-១៩៨៦ នៅក្នុង GATT មានកិច្ចប្រជុំចប់ពេញលេញ ចំនួនប្រាំពីរលើក ។

១៩៤៦ គេបានបូកបន្ថែម "ផ្នែកទី IV" នៃ GATT ដើម្បីផ្តល់ប្រព្រឹត្តកម្មពាណិជ្ជកម្ម អនុគ្រោះចំពោះប្រទេសកំពុងអភិវឌ្ឍ ជាពិសេស ដើម្បីអាចឱ្យគេទទួលផលប្រយោជន៍ ពីការនាំចូលនៅក្នុងការចរចារពាណិជ្ជកម្ម ដោយមិនចាំបាច់ផ្តល់ការអនុគ្រោះសងវិញ ។

១៩៧៣ គេបានបន្ថែម "ប្រយោគបង្កលក្ខណៈងាយស្រួល" ទៅក្នុង GATT ដើម្បីបង្កើតគំរោងការអនុគ្រោះផ្នែកច្បាប់ ចំពោះប្រទេសកំពុងអភិវឌ្ឍ ។ គំរោងការទាំងនេះ ដូចជា GSP ជាដើមមានលក្ខណៈផ្ទុយគ្នាជាមួយវិធានស្តីពី MFN ។

១៩៨៦ កិច្ចប្រជុំនៅប្រទេសអ៊ុយរូហ្កាយ (Uruguay) បានប្រព្រឹត្តទៅនៅទីក្រុង Punta del Exte អាណិត្តរបស់កិច្ចប្រជុំនេះមានទំហំធំជាងពេលណាៗទាំងអស់ រួមបញ្ចូលទាំងវិធាននានាទាក់ទងនឹងពន្ធនាំចូល និងអ្វីដែលមិនមែនជាពន្ធនាំចូលផងដែរ ។ ប៉ុន្តែ កិច្ចប្រជុំនេះក៏បាន ពង្រីកប្រព័ន្ធធ្វើពាណិជ្ជកម្មទៅកាន់វិស័យថ្មីៗនៃពាណិជ្ជកម្មផងដែរ ដូចជា សេវាកម្ម និងសិទ្ធិបញ្ញា ។ ក្រៅពីនេះវាជាកិច្ចប្រជុំដែល រៀបចំសាជាថ្មីទាំងស្រុង នូវប្រព័ន្ធដោះស្រាយវិវាទ និង បង្កើតអង្គការពាណិជ្ជកម្មថ្មីមួយសំរាប់ជំនួស GATT ដែលមាន "លក្ខណៈបណ្តោះអាសន្ន " ។

១៩៩៣ ថ្ងៃទី ២០ ខែធ្នូ ឈានដល់មានកិច្ចព្រមព្រៀងស្តីពីឯកសារទាំងអស់ នៃកិច្ចប្រជុំនៅប្រទេសអ៊ុយរូហ្កាយ (Uruguay) ។ អត្ថបទច្បាប់សន្យាថ្នាក់ជាតិ ស្តីពីទំនិញ ព្រមទាំង សេវាកម្មដែលមានចំនួន ២៣ 000 ទំព័រ ។

១៩៩៥ "កិច្ចព្រមព្រៀងទីក្រុងម៉ារ៉ាកេស (Marakesh)" (ប្រទេសម៉ារ៉ុក) ស្តីពីការបង្កើតអង្គការពាណិជ្ជកម្មពិភពលោកបានចូលជាធរមាន ។

១៩៩៥-២០០៥ ការអនុវត្តកិច្ចព្រមព្រៀងភាគច្រើន ស្តីពីសេវាហិរញ្ញវត្ថុ និងសេវាទូរគមនាគមន៍ជាមូលដ្ឋាន ។

១៩៩៩ កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីនៃ នៅទីក្រុងសេអាថល (Seattle) សហរដ្ឋអាមេរិក ពុំអាចប្រកាសបើកកិច្ចប្រជុំពាណិជ្ជកម្មថ្មីមួយបានឡើយ ។

២០០១ ប្រទេសចិនក្លាយជាសមាជិកនៃអង្គការ WTO បន្ទាប់ពីឆ្លងកាត់ការចរចារអស់ពេល ១៥ ឆ្នាំ ។

២០០១ សន្និសិទ្ធថ្នាក់រដ្ឋមន្ត្រីនៃអង្គការ WTO ប្រកាសបើកកិច្ចប្រជុំនៅទីក្រុងដូហា (Doha)។

២០០៤ ប្រទេសកម្ពុជាក្លាយជាសមាជិកទី ១៤៨ របស់អង្គការ WTO ។

## II. គោលបំណង និង មុខងាររបស់ WTO

តាមកិច្ចព្រមព្រៀង Marrakesh ស្តីពីការបង្កើត WTO និងកិច្ចព្រមព្រៀងWTO: អង្គការពាណិជ្ជកម្មពិភពលោកគឺ ជាអង្គការកំពូលមួយទទួលខុសត្រូវ ក្នុងការពិនិត្យមើលការអនុវត្តន៏ កិច្ចព្រមព្រៀង ពហុភាគី និងច្រើនភាគី ដែលបានលើកមកចរចារនៅវគ្គចរចារនៅយូរ៉ូហ្គាយ និងខ្លះទៀតត្រូវលើកយកមកចរចារនាពេល អនាគតខាងមុខ។

### ក. គោលការណ៏ និងគោលបំណង

#### ១. គោលការណ៏

គោលបំនងជាមូលដ្ឋានរបស់អង្គការពាណិជ្ជកម្មពិភពលោកគឺស្រដៀងគ្នាទៅនិង GATT ( កិច្ចព្រមព្រៀងស្តីពីពន្ធគយនិងពាណិជ្ជកម្ម) ដែលក្រោយមក GATT បានរួមបញ្ចូលតាមផ្លូវច្បាប់ទៅជា WTO។ មានការពង្រីកកម្មវត្ថុទាំងឡាយរបស់ WTO ដើម្បីផ្តល់អំណាចឱ្យអង្គការនេះដោះស្រាយកិច្ចការពាណិជ្ជកម្មលើសេវាកម្ម។

គោលបំណងសំខាន់បន្ថែមទៀតគឺ ដើម្បីជុំរុញដល់ការអភិវឌ្ឍន៏សេដ្ឋកិច្ចតាមរយះការពង្រីក ផ្នែកពាណិជ្ជកម្ម ហើយក៏មានការយកចិត្តទុក ដាក់ជាសំខាន់ផងដែរដល់កិច្ចការពារបរិស្ថាន។

កិច្ចព្រមព្រៀងទាំងអស់របស់WTOមានវិធានការសំខាន់ជាមូលដ្ឋាន៤យ៉ាងគឺ:

**ច្បាប់ និង បទប្បញ្ញត្តិនានាមានតម្លាភាព**

តម្លាភាព គឺជាគោលការណ៏ចំបងរបស់ WTO។ សំរាប់ពាណិជ្ជករ គ្មានអ្វីដែលមានសារៈសំខាន់ជាងការយល់ដឹង និងទំនុកចិត្តរបស់ពួកគេ ទៅលើបរិយាកាសច្បាប់ដែលពួកគេដំណើរការឡើយ ទោះជានៅក្នុងប្រទេស និងនៅក្រៅប្រទេសក្តី។ តាមធម្មតាកិច្ចព្រមព្រៀងត្រូវតែមានតម្លាភាព ហើយតំរូវឱ្យរដ្ឋាភិបាល និងអាជ្ញាធរដទៃទៀតបោះផ្សាយនូវច្បាប់វិធាន និងកិច្ចប្រតិបត្តិ នានាដែលអាចមានផលប៉ះពាល់ដល់ ពាណិជ្ជកម្ម រឺ ការវិនិយោគ។

បញ្ញត្តិបែបនេះមានសារៈសំខាន់ទាំងចំពោះក្រុមហ៊ុនដែលកំពុងដំណើរការក្នុងប្រទេស និងទាំងក្រុមហ៊ុនដែលមានបំនងចង់ចូលរកស៊ីនៅក្នុងប្រទេស។ ក្រុមហ៊ុនទាំងអស់ដែលដំណើរការនៅកម្ពុជា គួរដកពិសោធក្នុងការបើកចំហក្របខ័ណ្ឌគ្រប់គ្រងដោយបទបញ្ញត្តិ ចំពោះអាជីវកម្ម។ ប្រសិនបើ គ្មានការ ផ្លាស់ប្តូរទាំងនេះទេ ចំណាយដែលគេឃើញ គេមើលមិនឃើញ និងការបង់ប្រាក់ក្រៅផ្លូវការនានានឹងកាន់ តែធ្វើឱ្យមានឧបសគ្គចំពោះកិច្ចអភិវឌ្ឍ និង ចំពោះក្រុមហ៊ុនអន្តរជាតិធំៗ ដែលគ្រោងនឹងមកបើកអាជីកម្មនៅកម្ពុជាដែល តាមធម្មតាពួកគេគ្មាន

ឆន្ទៈទទួលយកនូវការធ្វើបែបនេះទេ។ ការបើកចំហទីផ្សារនៅក្នុង WTO តំរូវឱ្យមានការបើកចំហផ្នែកបទបញ្ញត្តិ និងការគ្រប់គ្រងដោយច្បាប់។

**ភាពរើសអើង**

គោលការណ៍សំខាន់ទី ២ នៃវិធានរបស់ WTO គឺ *ការមិនរើសអើង* ។ គេអនុវត្ត គោលការណ៍នេះជាពីរកំរិត។

- កំរិតទី ១ : ការមិនរើសអើង មានន័យថា គេមិនអាចរើសអើង ប្រឆាំងនឹងទំនិញកម្ពុជា នៅក្នុងទីផ្សារនាំចេញធៀបនឹងទំនិញដូចគ្នា ដែលនាំមកពីប្រទេស ប្រកួតប្រជែងនានាឡើយ។

- កំរិតទី ២ : នៅពេលណាដែលទំនិញនោះចូលទៅដល់ទីផ្សារនាំចេញ គេមិនអាចរើសអើងចំពោះទំនិញកម្ពុជា ខុសពីទំនិញដែលផលិតនៅក្នុងសាមីប្រទេសឡើយ។

ទម្រង់ទី ១ ស្ដីពីការមិនរើសអើង ត្រូវគេឱ្យឈ្មោះថា "ប្រទេសដែលបានទទួល ការអនុគ្រោះពាណិជ្ជកម្មបំផុត " (MFN) ។ មានន័យថា នៅក្នុងទីផ្សារនៃសមាជិក WTO គេមិនត្រូវចាត់ទុកទំនិញ កម្ពុជាខុសពីទំនិញរបស់សមាជិក WTO ដទៃទៀតឡើយ។

ទម្រង់ទី ២ នៃការរើសអើង ហៅថា ប្រព្រឹត្តកម្មធម្មជាតិ។ នេះគឺជាកិច្ចការពារ ដែលមានសារៈសំខាន់មួយចំពោះស្ថានភាពដែលទិញទំនិញនានា អាចចូលទៅកាន់ទីផ្សារមួយ ប៉ុន្តែបន្ទាប់មកគេធ្វើមិនឱ្យមានលក្ខណៈប្រកួតប្រជែង ព្រោះថាទំនិញទាំងនោះត្រូវជាប់ពន្ធជាប់បន្ទុក វិកិច្ចប្រតិបត្តិផ្នែករដ្ឋបាល ពិសេសដែលគេមិនអនុវត្តចំពោះផលិតផលប្រភេទដូចគ្នាដែលផលិតក្នុងប្រទេស។ ការធានាអំពីប្រព្រឹត្តិកម្មធម្មជាតិ និងជួយទំនិញកម្ពុជា នៅក្នុងទីផ្សារនាំចេញ ។ ស្របជាមួយគ្នានេះ គេត្រូវប្រើប្រាស់ប្រព្រឹត្តកម្មធម្មជាតិក្នុងប្រទេស ក្នុងការសម្របខ្លួនជាមួយការប្រកួតប្រជែង លើការនាំចូល។

ឧទាហរណ៏: ប្រទេសជប៉ុនបានបញ្ចុះពន្ធគយលើមុខទំនិញអង្ករពី ២០០% ទៅ ១៥០% សំរាប់អង្ករនាំចូលពីប្រទេសថៃ ប្រទេសជប៉ុន ក៏ត្រូវយកពនលើអង្ករប្រភេទដូចគ្នាដែលនាំចូលទៅ ប្រទេសជប៉ុន ពីប្រទេសសមាជិកដទៃទៀតតាមអត្រា១៥០%ដូចគ្នាដែរ។

**សេរីការភាវូបនីយកម្មពាណិជ្ជកម្មជាជំហាន១**

គោលការណ៏ទី ៣ គឺជាការធ្វើសេរីភាវូនីយកម្មពាណិជ្ជកម្មជាជំហាន១ តាមរយះការចរចារ។ WT0 ពុំមែន ជាកិច្ចព្រមព្រាងពាណិជ្ជកម្មសេរីឡើយ។ ដូចមានបញ្ជាក់ក្នុងជំពូកបន្តបន្ទាប់ គេឃើញមានដែននៃវិធានការសំរាប់ការពារទីផ្សារ ទប់ទល់និងការប្រកួតប្រជែងពីសំនាក់ការនាំចូល។ ប៉ុន្តែគោលដៅជាមូលដ្ឋាននៃ WTO គឺត្រូវបង្កើនពាណិជ្ជកម្ម និងការវិនិយោគទន់ តាមរយៈការបង្កើតទូលាយទីផ្សារ។

រាជរដ្ឋាភិបាលមានសេរីភាព ក្នុងការបើកទូលាយសេរីភាពទីផ្សាររបស់ខ្លួន ដែលមានលក្ខណៈឯករាជ្យពី WTO បន្ទាប់ពីចូលរួមក្នុងអង្គការ WTO។ ប្រទេសកម្ពុជា អាចធ្វើសេរីភាវូបនីយកម្ម បន្ថែមទៀត ក្នុងកំរិតរាជរដ្ឋាភិបាលអាចយល់ ស្របបាន។

ក្នុងរយៈពេលប្រហែល ១០ ឆ្នាំម្តង GATT និង WTO តែងតែប្រកាសរៀបចំកិច្ចប្រជុំពាណិជ្ជកម្មពហុភាគី ដែលបណ្តាប្រទេសជាសមាជិកចូលរួមចរចារទូទៅដ៏ទូលំទូលាយ ដើម្បីបើកទីផ្សាររបស់ប្រទេសនីមួយៗ រឺពង្រីកដែនគ្រប់ដណ្តប់នៃវិធាននានា។ អង្គការនេះត្រូវបង្កើតឡើង ដោយកិច្ចប្រជុំនៅទីក្រុង អ៊ុយរូហ្គាយ (Uraguay) ដែលមានរយះពេលពីឆ្នាំ ១៩៨៦ ដល់ ១៩៩៤។

## ប្រព្រិត្តិពាណិជ្ជកម្មពិសេស និងដាច់ដោយឡែក

គោលការណ៍ទី ៤ គឺ "ប្រព្រិត្តិពាណិជ្ជកម្មពិសេស និងដាច់ដោយឡែក" សំរាប់ប្រទេស កំពុងអភិវឌ្ឍ។ ក្នុងការអនុវត្តន៏ជាក់ស្តែង ទស្សនាទាននេះអនុញ្ញាតឱ្យមាន លក្ខខ័ណ្ឌងាយស្រួល ចំពោះប្រទេសក្រីក្រ។ ប្រការនេះអាចមានន័យថា មិនអនុម័តបញ្ញត្តិមួយចំនួននៃកិច្ចព្រមព្រៀងថ្មីចំពោះ ប្រទេសក្រីក្រច្រើនជាងពេលវេលាដែលត្រូវផ្តល់អោយប្រទេសរីកចំរើន។ នេះជាទិដ្ឋភាពមួយ មានសារះសំខាន់នៃកិច្ចការនៅទីក្រុងដូហា (Doha) ។

ក្នុងនាមជាប្រទេសមានការអភិវឌ្ឍន៏ទាបបំផុតមួយ ប្រទេសកម្ពុជានិងពិនិត្យឃើញថា ខ្លួនស្ថិតក្នុងបញ្ញត្តិដែលមាន ប្រព្រឹត្តកម្មពាណិជ្ជកម្មពិសេសជាច្រើន។

ឧទាហរណ៏ៈ កម្ពុជាអាចរួចផុតពីការ តម្រូវឱ្យអនុវត្តបញ្ញត្តិ WTO មួយចំនួនក្នុងពេលអនាគត ឬបានទទួលពេលវេលាបន្ថែមទៀត សម្រាប់អនុវត្តបញ្ញត្តិទាំងនោះមិនដូចសមាជិក ឯទៀតៗទេ ។ ជាងនេះទៅទៀត នៅក្នុងការចរចារពាណិជ្ជកម្ម តាមធម្មតាគេមិនតម្រូវឱ្យកម្ពុជាធ្វើវិភាគទានជាចំបង ក្នុការផ្តល់លទ្ធភាពចូលទៅកាន់ទីផ្សារថ្មីដែលផ្តល់ផលប្រយោជន៏ដល់សមាជិកឯទៀតឡើយ ។បញ្ហាសម្រាប់ ក្រុមហ៊ុនឯកជននៅកម្ពុជា គឺតើល័ក្ខខ័ណ្ឌបែបនេះក្នុងរយៈពេលវែងអាចជួយ ឬធ្វើឱ្យប៉ះពាល់ដល់ការអភិវឌ្ឍន៏សម្ថភាពប្រកួតប្រជែងដ៏រឹងមាំក្នុងវិស័យកសិកម្ម កម្មន្តសាល និងសេវាកម្ម ដែរឬទេ?

ក្រៅពីគោលការណ៏មូលដ្ឋានទាំងបួន ដូចបានរៀបរាប់ខាងលើអង្គការ WTO មានគោលការណ៏ទូទៅបន្ថែមទៀតសំរាប់ការអនុវត្តន៏មួយចំនួនទៀតដែលយើង និង យកមកបកស្រាយនូវអត្ថបទបន្តបន្ទាប់នៅពេលខាងមុខ។

- ប្រទេសជាសមាជិក អាចការពារឧស្សាហកម្មក្នុងស្រុក តាមរយះការកំណត់ពន្ធគយលើទំនិញនាំចូលតែពុំការពារបានតាមរយះការកំណត់ ឬវិធានការពុំមែនពន្ធគយផ្សេងទៀតនោះទេ ។ ក៏ប៉ុន្តែមានករណីខ្លះអាចអនុញ្ញាតបានដែរ ។ ប្រទេសជាសមាជិកក៏ត្រូវបានបង់ឱ្យបន្ថយពន្ធលើទំនិញនាំចូលតាមការដែលអាចធ្វើបានហើយពន្ធ លើមុខទំនិញទាំងនោះ ត្រូវចងក្នុងកំរិតមួយសមស្រប។

ឧទាហរណ៍: ប្រទេសម៉ុងហ្គោលីនៅពេលក្លាយជាសមាជិក WTO នៅឆ្នាំ ១៩៩៧ ត្រូវចងពន្ធគយ លើមុខទំនិញកំរាលព្រំស្មើនិង ៤០% រីឯពន្ធគយលើស្ថាប័នគយយកលើមុខទំនិញកំរាលព្រំសព្វថ្ងៃគឺតែ ២០% ប៉ុណ្ណោះ។ ពន្ធគយដែលបានចងនោះ (Bound trariff rafe) គឺជាពន្ធដំបូងដែលប្រទេស ម៉ុងហ្គោលីពុំអាចតំឡើង លើសពី៤០% ឡើយនៅពេលខ្លួនមានមូលហេតុសមរម្យចង់តំឡើងលើមុខទំនិញកំរាលព្រំនោះ។

- ប្រទេសជា សមាជិកទាំងអស់ត្រូវតែគោរពលើគោលការណ៍សំខាន់មួយទៀត ដែលហៅថាប្រព្រឹត្តកម្មជាតិ (National Trealment) មានន័យថាប្រទេសទាំងអស់ត្រូវតែអនុវត្ត ដូចគ្នាដោយគ្មានការបែងចែកចំពោះទំនិញនាំចូលក៏ដូចជាទំនិញផលិតផលក្នុងស្រុកឡើយ។ឧទាហរណ៍ថាបើ ប្រទេសមួយយកពន្ធ លើការប្រើប្រាស់លើទំនិញនាំចូល ១០% គេក៏ត្រូវយកពន្ធលើទំនិញក្នុងស្រុក ១០% នៃទំនិញដែលមានប្រភេទដូចគ្នា។ ពោល គឺគេត្រូវប្រព្រឹត្តដូចគ្នាដោយ មិនរើសអើងឬបែងចែកថា ទំនិញនាំចូលត្រូវយកពន្ធខុសពីទំនិញផលិតផលក្នុងស្រុកឡើយ។

### **២. គោលបំណងរបស់** WTO

នៅក្នុងបុព្វកថានៃកិច្ចព្រមព្រៀងបង្កើត អង្គការពាណិជ្ជកម្មពិភពលោក មានចែកពីគោលបំណងរបស់ WTO ដូចជា លើកកំពស់ជីវភាពរស់នៅនិងចំណូលនានា ធានាឱ្យមានការងារធ្វើពេញលេញ ពង្រីកផលិតកម្ម និងពាណិជ្ជកម្ម អនុវត្តន៍ឱ្យមានការប្រើប្រាស់ធនធានពិភពលោកប្រកបដោយប្រសិទ្ធិភាព និងអស់សក្តានុពល។

បុព្វកថាបានពង្រីកបន្ថែមគោលបំណងទៅលើវិស័យមួយចំនួនដូចខាងក្រោម:

- ពាណិជ្ជកម្មលើសេវាកម្ម

- សេចក្តីត្រូវការសំរាប់ជំរុញនិរន្តរភាពនៃការអភិវឌ្ឍន៍ និងការពារបរិស្ថានតាមរបៀបមួយសមស្របទៅតាមកំរិតនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិនីមួយៗ ។

- សេចក្តីត្រូវការចំពោះការខិតខំជាវិជ្ជមាន ដើម្បីធានាថាប្រទេសកំពុងអភិវឌ្ឍន៍និងប្រទេសក្រីក្រមានការអភិវឌ្ឍន៍ និង មានកំនើនសេដ្ឋកិច្ចផងដែរ ក្នុងការចូលរួមក្នុងកិច្ចចរចារពាណិជ្ជកម្មអន្តរជាតិ។

### **៥. មុខងារ**

កិច្ចព្រមព្រៀងបង្កើតអង្គការ WTOបានចែងថា អង្គការនេះមានមុខនាទីដូចខាងក្រោម:

- ទី ១: ត្រូវផ្តល់ជាអទិភាពសំរាប់ការចរចារបន្តទៀតទៅក្នុងចំណោម ប្រទេសជាសមាជិកនូវបញ្ហាផ្សេងៗដែលមានចែងក្នុងកិច្ចព្រមព្រៀង និងអំពីបញ្ហាថ្មីនានាដែលស្ថិតក្នុងអំណាចរបស់ខ្លួន ព្រមទាំងអំពីការធ្វើសេរីភាវូបនីយកម្មផ្នែកពាណិជ្ជកម្មបន្ថែមទៀត។

- ទី ២: ត្រូវជួយសំរួលដល់ការអនុវត្តន៍ការគ្រប់គ្រង និងប្រតិបត្តិការនៃប្រតិបត្តិការនៃឯកសារគតិយុត្តនាកិច្ចប្រជុំចរចារ យូរ៉ូហ្គាយ និងរាល់កិច្ចព្រមព្រៀងទាំងឡាយដែលបានចរចារនិងបានអនុម័តក្នុងកិច្ចចរចារនាពេលអនាគត។

- ទី ៣: ត្រូវទទួលខុសត្រូវលើការសំរបសំរួល ការខ្វែងគំនិតគ្នា និងវិវាទនៅក្នុងចំណោមប្រទេសជាសមាជិក

- ទី ៤: ត្រូវទទួលខុសត្រូវ លើការត្រួតពិនិត្យជាប្រចាំ ចំពោះគោលនយោបាយពាណិជ្ជកម្ម របស់បណ្ដាប្រទេសជាសមាជិក។

## III. រចនាសម្ព័ន្ធអង្គការពាណិជ្ជកម្មពិភពលោក

### ក. សន្និសិទ្ធិថ្នាក់រដ្ឋមន្រ្តី

អង្គការក្នុងលោកធ្វើការតាមការរចនាសម្ព័ន្ធដូចខាងក្រោម:

អង្គការកំពូលរបស់អង្គការ WTO គឺសន្និសិទ្ធិថ្នាក់រដ្ឋមន្រ្តីដែលធ្វើការប្រជុំរវាងពីរឆ្នាំម្ដងដើម្បីសំរេចនូវរាល់នយោបាយពាណិជ្ជកម្ម និងការចរចារតាមវិស័យផ្សេងៗ ដែលលើកឡើងដោយអង្គការថ្នាក់ក្រោម។ តាំងពីអង្គការ WTO ចាប់កំនើតនៅឆ្នាំ១៩៩៥អង្គការនេះបានធ្វើការប្រជុំសន្និសិទ្ធិ ថ្នាក់រដ្ឋមន្រ្តីរបស់ខ្លួនចំនួនបួនដងរួចមកហើយ។ សន្និសិទ្ធិទី១ ធ្វើនៅប្រទេសសាំងហ្គពួរពីថ្ងៃទី០៩ ដល់ ១៣ ធ្នូឆ្នាំ១៩៩៦ លើកទីពីរនៅទីក្រុង ហ្សឺណែវ ប្រទេស ស្វីស នាខែ ឧសភា ឆ្នាំ១៩៩៨ លើកទីបីនៅទីក្រុងសៀអាថល ប្រទេសអាមេរិចពីថ្ងៃទី ៣០ ខែ វិច្ឆិការដល់ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងសន្និសិទ្ធិលើកទីបួនធ្វើនៅទីក្រុង ដូហា ប្រទេស ក្វាតា (បែកអារាប់) ពីថ្ងៃទី ០៩ ដល់ថ្ងៃទី ១៣ ខែ វិច្ឆិការ ឆ្នាំ ២០០១ ។

### ខ. អគ្គក្រុមប្រឹក្សា

ស្ថាប័ន អង្គភាពបន្ទាប់ពីសន្និសិទ្ធិថ្នាក់រដ្ឋមន្រ្តីមកគឺ អគ្គក្រុមប្រឹក្សា។ អគ្គក្រុមប្រឹក្សា ធ្វើការងារទូទៅដោយទទួលរបាយការណ៍ ពីក្រុមប្រឹក្សាថ្នាក់បន្ទាប់ផ្សេងទៀត និង បើកកិច្ចប្រជុំដើម្បី ដោះស្រាយវិវាទ ពាណិជ្ជកម្ម និងត្រួតពិនិត្យនយោបាយពាណិជ្ជកម្ម របស់បណ្ដាប្រទេសជាសមាជិកនីមួយៗជាប្រចាំ ។

- ក្នុងចន្លោះពេលពីរឆ្នាំនៃកីច្ចប្រជុំ អគ្គក្រុមប្រឹក្សាដើរតួនាទី ជាអង្គភាពសំខាន់ក្នុងការអនុវត្តមុខងាររបស់ខ្លួន ។

- អគ្គក្រុមប្រឹក្សា ជួបប្រជុំក្នុងនាមជាអង្គភាពសំរបសំរួលវិវាទនៅពេលបានទទួលបណ្ដឹងតវ៉ាមកពិនិត្យ ពិចារណា និងប្រកាន់យកវិធានការដោះស្រាយវិវាទប្រទេសជាសមាជិក។ អគ្គក្រុមប្រឹក្សាទទួលខុសត្រូវផងដែរក្នុងការពិនិត្យមើលនយោបាយពាណិជ្ជកម្មរបស់ប្រទេសនីមួយៗផ្អែកតាមរបាយណ៏ដែលរៀបចំដោយលេខាធិដ្ឋាន WTO។

### គ. ក្រុមប្រឹក្សាពាណិជ្ជកម្មលើទំនិញ

ស្របតាមមាត្រា៤:៥ នៃកិច្ចព្រមព្រៀង WTOក្រុមប្រឹក្សាពាណិជ្ជកម្ម លើទំនិញជាអ្នកឃ្លាំមើលការអនុវត្ត និង កិច្ចប្រជុំដំណើរការកិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤ និងកិច្ចព្រមព្រៀងពាក់ព័ន្ធនានា ។

### ឃ. ក្រុមប្រឹក្សាពាណិជ្ជកម្មលើសេវាកម្ម

យោងតាមមាត្រា៤:៥ នៃកិច្ចព្រមព្រៀង WTO ក្រុមប្រឹក្សាពាណិជ្ជកម្មលើសេវាកម្មជាអ្នកឃ្លាំមើលការអនុវត្តន៍ និងកិច្ចដំណើរការនៃកិច្ចព្រមព្រៀង GATTS ។

### ង. ក្រុមប្រឹក្សាផ្នែកកម្មសិទ្ធបញ្ញា

ក្រុមប្រឹក្សានេះគឺ ជាអ្នកឃ្លាំមើលកិច្ចដំណើរការនៃកិច្ចព្រមព្រៀង TRIPS(មាត្រា៤:៥ នៃកិច្ចព្រមព្រៀង WTO) ។ ក្រៅពីក្រុមប្រឹក្សាទាំង ៣ ខាងលើនេះគេមានបង្កើតគណកម្មាធិការមួយចំនួនទៀតតាមការពាក់ព័ន្ធនៃកិច្ចព្រមព្រៀងនីមួយៗ ដើម្បីទទួលយកការងារមកពិនិត្យ និងដោះស្រាយទៅតាមកិរិតនីមួយៗ នៃការអនុវត្តន៍របស់កិច្ចព្រមព្រៀង ។

### ច. អង្គភាពដោះស្រាយវិវាទ

កិច្ចព្រមព្រៀងអង្គការ WTO មានចែងពីប្រព័ន្ធវិធាន និងនីតិវិធីរួមមួយសំរាប់អនុវត្តវិវាទដែលកើត ឡើងនៅក្រោមលិខិតតុបករណ៍ច្បាប់ណាមួយរបស់ខ្លួន ។ ការទទួលខុសត្រូវសំខាន់សំរាប់គ្រប់គ្រងវិធាន និងនីតិវិធីទាំងនេះស្ថិតនៅលើអគ្គក្រុមប្រឹក្សាដែលបានកំនត់សំគាល់ពីដំបូងថា មានតួនាទីជាអង្គភាពដោះស្រាយវិវាទ (DSB) ។ គោលការណ៍សំខាន់មួយចំនួនក្នុងចំណោមគោលការណ៍សំខាន់ដ៏ទៃទៀតដែលនីតិវិធីទាំងនេះបានកំណត់គឺថារដ្ឋាភិបាលនៃប្រទេសជាសមាជិកគួដាក់វិវាទជូនអង្គភាពដោះស្រាយវិវាទ ដើម្បីដោះស្រាយបន្ទាប់ពីបរាជ័យក្នុងការ ប្រឹងប្រែងដោះស្រាយតាមរយះការពិគ្រោះយោបល់ ។ នីតិវិធីបានចែងផងដែរថា ដើម្បីសំរេចបានដំណោះស្រាយមួយដែលអាចទទួលយកបានទាំងសងខាងភាគីទាំងពីរ អាចធ្វើដំណើរទៅអគ្គលេខាធិការអង្គការ WTO រឺបុគ្គលដ៏ទៃទៀតដើម្បីប្រើប្រាស់សមត្ថភាព និងកេរ្តិ៍ឈ្មោះរបស់គាត់ផ្សះផ្សា និងសំរុះសំរួលរវាងភាគីជំលោះ ។

នៅពេលដែលមានការពិគ្រោះយោបល់ រឺការប្រឹងប្រែងពិគ្រោះយោបល់មិនសំរេចបានលទ្ធផលតាមបំណងនៅក្នុងអំឡុងពេល ៦០ ថ្ងៃ ភាគីប្តឹងអាចសំណើរទៅអង្គការដោះស្រាយវិវាទផ្លូវការ ដើម្បីចាប់ផ្តើមធ្វើយន្តការដោះស្រាយវិវាទដោយបង្កើត គណវិនិច្ឆ័យពិនិត្យមើលពាក្យបណ្តឹង តែលុះត្រាតែមានការព្រមព្រៀងលើការបង្កើតដូចគ្នានោះ ។ ដើម្បីបង្កើនការដោះស្រាយជំលោះឱ្យបានលឿ និងធានាបង្កើតគណៈវិនិច្ឆ័យដោយមិនបង្អែរបង្អង់ដោយប្រទេសដែលបានទទួលពាក្យបណ្តឹងនីតិវិធីតំរូវឱ្យអង្គការដោះស្រាយវិវាទបង្កើត ជាគណៈវិនិច្ឆ័យនៅពេលដែលស្នើរឡើងដោយប្រទេសប្តឹង លើកលែងតែមានមតិរួមប្រឆាំងនឹងការបង្កើតគណៈវិនិច្ឆ័យនោះ ។

ជាធម្មតាគណៈវិនិច្ឆ័យមានសមាជិកចំនួន ៣ រូបលើកលែងតែភាគីជំលោះយល់ព្រមថាគួមាន ៥ រូប ។ ឈ្មោះបុគ្គលដែលត្រូវតែងតាំងនៅក្នុងគណៈវិនិច្ឆ័យ គឺស្នើរឡើងដោយលេខាធិការដ្ឋានអង្គការពាណិជ្ជកម្មពិភពលោកលើបញ្ជីឈ្មោះ ដែលរក្សាទុកដោយអង្គការនេះ រួមមានជំនាញការមកពីខាងរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ។ បុគ្គលនៅក្នុងបញ្ជីឈ្មោះ គឺជាមន្ត្រីជាន់ខ្ពស់មានសមត្ថភាពរបស់ប្រទេសជាសមាជិក គណៈប្រតិភូប្រចាំអង្គការ WTOមន្ត្រីជាន់ខ្ពស់ដែលធ្លាប់បង្រៀនច្បាប់ និងគោលនយោបាយពាណិជ្ជកម្មអន្តរជាតិ ។

សមាជិកភាពរបស់គណៈវិនិច្ឆ័យ ជាធម្មតាត្រូវជ្រើសដោយមាន ការពិគ្រោះយោបល់ជាមួយភាគីចំពោះ ។ គណៈវិនិច្ឆ័យជាទូទៅ តំរូវឱ្យដាក់របាយការណ៍ដែលរួមមានអនុសាសន៍របស់ពួកគេ និងការវាយតំលៃអង្គនៃរឿងក្តី ដោយមិនលំអៀង ស្របនឹងវិធានការដែលបានប្តឹងអំពីអ្វីដែលពាក់ព័ន្ធ និងបទបញ្ញត្តិនៃលិខិតតុបករណ៍ច្បាប់ជូនអង្គភាពដោះស្រាយវិវាទនៅក្នុងអំឡុងពេល៦ ទៅ ៩ ខែ ។ ការបង្កើតអង្គភាពឧទ្ធរណ៍ ដែលមានលក្ខណៈដូចតុលាការឧទ្ធរណ៍គឺជា ការបន្ថែមថ្មីពីលើប្រព័ន្ធវិវាទ ។ អង្គភាពនេះរួមមានបុគ្គលិកចំនួន ៧ នាក់ និងជាអាជ្ញាធរដែលគេទទួលស្គាល់ថា មានជនានាញច្បាស់ពាណិជ្ជកម្មអន្តរជាតិ និងប្រធានបទផ្សេងទៀតដែលគ្របដណ្តប់ដោយកិច្ចព្រមព្រៀងនេះ។ អង្គភាពនេះមិនមែនជាសាខារបស់រដ្ឋាភិបាលណាមួយនោះឡើយ។ ក្នុងចំណោម ៧ នាក់ មានតែ ៣ នាក់ទេត្រូវបានកោះអញ្ជើញឱ្យបំរើក្នុងរឿងក្តីណាមួយនោះ ។ បណ្តឹងឧទ្ធរណ៍អាចធ្វើឡើងដោយភាគីជំលោះណាមួយក៏បាន ។របាយការណ៍របស់អង្គភាពឧទ្ធរណ៍ និងត្រូវកំណត់ទៅលើតែអង្គច្បាប់ក្នុងនយោបាយរបស់គណៈវិនិច្ឆ័យ និងការបកស្រាយអំពីច្បាប់ដែលបង្កើតដោយខ្លួនឯងផ្ទាល់ ហើយត្រូវដាក់ជូនអង្គភាពដោះស្រាយវិវាទក្នុងអំឡុងពេលពី ៦០ ទៅ ៩០ ថ្ងៃ ។

បន្ទាប់ពីចាប់កំណើតបាន ៨ ឆ្នាំមក តុលាការពាណិជ្ជកម្មពិភពលោកបានដោះស្រាយជំលោះចំនួន ២៤៣ ករណីអាមេរិចបានចំណាយពេលវេលាឥតប្រយោជន៍ចំនួន ៤ លើកក្នុងបំណងដាក់បញ្ចូលប្រការមួយដែលបង្កលក្ខណៈឱ្យពួកគេបញ្ចៀសបាននូវទណ្ឌកម្មរបស់ WTO ។ ចំនុចខ្សោយរបស់តុលាការនេះ គឺបញ្ហាពុំមាននូវវិធានការចាប់បង្ខំឱ្យអនុវត្តន៍សាលក្រមរបស់ពួកគេ ។ វាហាក់ដូចជាតុលាការមួយមិនអាចកេណ្ឌបាននូវកំលាំងរបស់ រដ្ឋអំណាចដើម្បីជំរុញជនល្មើសម្នាក់ចូលក្នុងពន្ធនាគា ។ ក្នុងចំណោមករណីទាំងឡាយដែលតុលាការ ពាណិជ្ជកម្មពិភពលោកបានកាត់ក្តីមាន ៤ ករណី ដែលតឹងតែងបំផុតគឺ:

១. ជំលោះអំពីបញ្ហាដែកថែបនៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០០២ ដែលភាគីម្ខាងគឺអាមេរិចនិងភាគីម្ខាងទៀតគឺ EU ជប៉ុន កូរ៉េខាងត្បូង ហើយសំរេចឱ្យអាមេរិចចាញ់ក្តី ។

២. បណ្តឹងអំពីការគាំទ្រតំលៃនាំចេញរបស់អាមេរិច(១៩៩២) រវាងអឺរ៉ុប និងអាមេរិច។ តុលាការ WTO បានអនុម័តទៅលើទណ្ឌកម្មរបស់អាមេរិចចំនួន ៤ លើក ជាបន្តបន្ទាប់ ។ នេះគឺជាក្តីក្តាំងធំផុតអំពីហិរញ្ញវត្ថុ។

៣. ករណីប្តឹងអំពីចេក(១៩៩៥)។ WTO បានកាត់ទោសចោទប្រកាន់ EU អំពីប្រព័ន្ធនាំចូលចេករបស់គេដែលបានធ្វើឱ្យអន្តរាយចំពោះបណ្តាប្រទេសទ្វីបអាហ្វ្រិច ហើយចាប់បង្ខំឱ្យ EU ត្រូវផ្លាស់ប្តូរប្រព័ន្ធនាំចូលចេករបស់គេ។

៤. សង្គ្រាមអំពីសាច់គោ ឆ្នាំ១៩៩៨ WTOបានកាត់ទោសចោទប្រកាន់ EU គឺបទហាមនាំចូលសាច់គោអ័រម៉ូនរបស់អាមេរិច ហើយដែលពួកគេមិនបានផ្តល់នូវតឹមតាងវិទ្យាសាស្ត្រណាមួយអំពី គ្រោះថ្នាក់របស់សាច់គោផ្ទុកអ័រម៉ូនអាមេរិច។ អាមេរិចបានឈ្នះក្តី។

**ឆ. លេខាធិការដ្ឋាន** WTO

អង្គការពាណិជ្ជកម្មពិភពលោកមាន លេខាធិការដ្ឋានមួយដែលមានទីតាំងនៅទីក្រុង ហ្សឺណែវ ប្រទេសស្វីស។ លេខាធិការដ្ឋាននេះដឹកនាំដោយអគ្គនាយកមួយរូបដែល ជ្រើសរើសតាមការបោះឆ្នោត និងមានអាណិត្តចំនួន ៥ ឆ្នាំ។ អគ្គនាយកអាចជ្រើសរើសអគ្គនាយករងចំនួន ៣ រូបទៀតដើម្បីជួយធ្វើការដោយមានការពិគ្រោះពិភាក្សា និងយល់ព្រមពីបណ្តុប្រទេសជាសមាជិក ។ មន្ត្រីចំរុះជាតិសាសន៍ ដែលធ្វើការនៅលេខាធិការដ្ឋានមានចំនួន ៥០០ នាក់ដែលភាគច្រើនចេះពីរឬបីភាសា (អង់គ្លេស បារាំង និងអេស្បាញ) ។ ថវិការរបស់លេខាធិការដ្ឋាន WTO សំរាប់ឆ្នាំ ២០០០ គឺមាន ១២៧លានហ្វ្រង់ស្វីសប្រហែលនឹង៨០លានដុល្លាអាមេរិច ។ ថវិការនេះបានមកពីវិភាគទានបង់ប្រាក់ដោយប្រទេសជាសមាជិកនិងប្រទេសអ្នកសង្កេតការណ៍ រួមទាំងថវិការជំនួយផ្សេងៗ ពីប្រទេសអង្គការសំខាន់ៗមួយចំនួនផងដែរ។

**ជ. សមាជិកភាព**

គិតដល់ថ្ងៃទី៤ ខែមេសា ឆ្នាំ ២០០៣ មានប្រទេសចំនួន ១៤៦ ជាសមាជិករបស់WTO និងកើនឡើងដល់ ១៤៨ នាឆ្នាំ ២០០៤។ ប្រទេស ដែលមានចេតនាចង់ចូលជាសមាជិកអង្គការ WTO ត្រូវដាក់ពាក្យសុំចូល និងធ្វើការចរចារជាលក្ខណះទ្វេ និងពហុភាគីសំរាប់បង្ហាញពីតម្លាភាព និងភាពស្របគ្នានៃបទបញ្ញតិច្បាប់របស់ជាតិទៅនឹងកិច្ចផ្សេងៗ (Commitments) ដូចជាកាត់បន្ថយពន្ធគយការធ្វើសេរីភាវូបនីយកម្មផ្នែកសេវាកម្មដែលប្រការនេះគេហៅថាកំរៃត្រូវបង់ដោយប្រទេសសុំចូលជាថ្មី និងការទទួលបានអត្ថប្រយោជន៍នានាពី WTO ។

**IV. លក្ខណៈសម្បត្តិដើម្បីក្លាយទៅជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក** WTO

មាត្រា ៧ នៃកិច្ចព្រមព្រៀង WTO ចែងថា ការចូលជាសមាជិកក្នុង WTO នឹងត្រូវធ្វើឡើងតាមរយៈលក្ខខ័ណ្ឌជាច្រើនដើម្បីឈានទៅរកការព្រមព្រៀងពីសមាជិក និងWTO ។ ការចូលជាសមាជិកនេះត្រូវការចាំបាច់ចូលជាសមាជិកអង្គការដទៃទៀតផ្សេងទៀត ដែលត្រូវបញ្ចូលជាស្វ័យប្រវត្តិ។

ក្រុមការងារនីមួយៗ ក្នុងអំឡុងពេលចេញសេចក្តីសំរេចតាមរយៈការព្រមព្រៀង ត្រូវតែមានការព្រមព្រៀងរវាងសមាជិកទាំងអស់របស់ WTO ដែលឆ្លើយតបទៅនឹងទឹកចិត្តផ្ទាល់ និងសំនួរដែលគេចោទឡើងជុំវិញការចរចារទ្វេភាគី និងពហុភាគី។

គ្រប់ឯកសារដែលរៀបចំឡើងដោយក្រុមការងារ ក្នុងអំឡុងពេលចរចារតូវធ្វើជាកម្មវត្ថុនៃការចែកចាយរហូតដល់ការបញ្ចប់នៃនីតិវិធី។

លក្ខខ័ណ្ឌនៃការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក WTO រួមមានៈ

**ក.បេក្ខភាព**

គ្រប់រដ្ឋ ឬដែនដីពន្ធគយដែលប្រើប្រាស់នូវស្វ័យភាពក្នុងការដឹកនាំនយោបាយពាណិជ្ជកម្មរបស់រដ្ឋ ឬដែនដីនោះ អាចចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក WTO បានដោយគ្រាន់តែបំពេញនូវលក្ខខ័ណ្ឌដែលឈានឆ្ពោះទៅរកការព្រមព្រៀង រវាងរដ្ឋនោះ ឬដែនដីនោះ និងសមាជិកទាំងអស់របស់អង្គការពាណិជ្ជកម្មពិភពលោក WTO ( មាត្រា ៧ នៃកិច្ចព្រមព្រៀង WTO) ។

**ខ.ការស្នើភាព**

នីតិវិធីនៃការចូលជាសមាជិកចាប់ផ្តើមតាមរយៈ ការបង្ហាញខ្លួនដោយការបំពេញ នូវពាក្យសុំជាផ្លូវការដោយរដ្ឋាភិបាលជាបេក្ខជន។ ពាក្យសុំនេះ ត្រូវរៀបចំឡើងដោយអគ្គក្រុមប្រឹក្សាដែលបានបង្កើតក្រុមការងារមួយសំរាប់ទទួលបន្ទុកក្នុងការរៀបចំសំណុំលិខិត ឬឯកសារ និងបង្ហាញសេចក្តីសន្និដ្ឋានសំរាប់ការយល់ព្រម ។ គ្រប់សមាជិកអង្គការពាណិជ្ជកម្មពិភពលោក WTO ទាំងអស់អាចចូលរួមជាមួយក្រុមការងារបាន។

**គ.ការបង្ហាញជំនួយការផ្នែកស្មារតី ស្តីពីរបបពាណិជ្ជកម្មក្រៅប្រទេស**

រដ្ឋាភិបាលជាបេក្ខជនបង្ហាញទៅអោយក្រុមការងារ នូវជំនួយការផ្នែកស្មារតីដែលបានធ្វើការវែកញែកនូវគ្រប់ផ្នែកនៃរបបពាណិជ្ជកម្មក្រៅប្រទេស និងរបបគតិយុត្តរបស់ប្រទេសនោះ។ ផ្អែកលើមូលដ្ឋាននៃជំនួយការផ្នែកស្មារតីនេះក្រុមការងារត្រូវធ្វើការវិភាគយ៉ាងលំអិតទៅលើអង្គហេតុ។

នៅពេលកិច្ចប្រជុំបន្ទាប់ ក្រុមការងាររៀបចមនូវសំនួរដែលចោទឡើងដោយសមាជិក WYO ដោយផ្អែកលើការបង្ហាញមួយដែល ត្រូវដាក់បញ្ចូលទៅក្នុងជំនួយការផ្នែកស្មារតី និងចំលើយដែលផ្តល់ដោយរដ្ឋាភិបាលជាបេក្ខជន។

**ឃ.លក្ខខ័ណ្ឌនៃការចូលជាសមាជិក**

ក្រោយពីបានរៀបចំគ្រប់ផ្នែកនៃរបបពាណិជ្ជកម្មក្រៅប្រទេស និងរបបគតិយុត្តរបស់រដ្ឋាភិបាលជាបេក្ខជនក្រុមការងារចាប់ផ្តើមបើកការចរចារពហុភាគី ចំពោះការចូលជាសមាជិក។ កិច្ចប្រជុំនេះអាចអោយយើងកំនត់បាននូវបៀប និងលក្ខខ័ណ្ឌដាក់បញ្ចូលសមាជិកភាព ទៅអោយរដ្ឋាភិបាលជាបេក្ខភាព។ របៀប និងលក្ខខ័ណ្ឌទាំងនេះរួមមានការព្រមព្រៀដែលទាក់ទងនឹងការគោរពនូវវិធាន បទបញ្ជារបស់អង្គការពាណិជ្ជកម្មពិភពលោក WTO ក្រោយពីការសុំចូលជាសមាជិក និងក្នុងអំឡុងពេលកែប្រែច្បាប់ ឬរចនាសម្ព័ន្ធចាំបាច់សំរាប់អនុវត្តកិច្ចព្រមព្រៀងទាំងនេះ។

**ង.ការចរចារទ្វេភាគី**

ក្នុងពេលដូចគ្នានេះដែរ រដ្ឋាភិបាលជាសមាជិកព្រមព្រៀងជាមួយ សមាជិករបស់ក្រុមការងារសាមីនៃការចរចារទ្វេភាគីលើការព្រមព្រៀងក្នុងផ្នែកទីផ្សារសំរាប់ទំនិញ និងសេវាកម្ម។ លទ្ធផលនៃកិច្ចចរចារទ្វេភាគីទាំងនេះត្រូវ បានគេប្រមូលផ្តុំក្នុងឯកថសារមួយ ដែលជាផ្នែកមួយនៃបណ្តុំលក្ខខ័ណ្ឌក្នុងការចូលជាសមាជិកពេញសិទ្ធិ។

**ច.ការយល់ព្រមតាមលក្ខខ័ណ្ឌនៃការចូលជាសមាជិកភាពដោយមានលក្ខខ័ណ្ឌ**

នៅពេលសេចក្តីព្រាងនៃរបាយការណ៍របស់ ក្រុមការងារប្រូតូកូលនៃការចូលជាសមាជិក បញ្ជីនៃការ ព្រមព្រៀងក្នុងផ្នែកទីផ្សារសំរាប់ទំនិញ និងសេវាកម្មត្រូវបានគេដាក់កំនត់ជាវិធានលើកិច្ចការសំរេចរបស់សមាជិកនៃក្រុមការងារ បណ្តាលក្ខខ័ណ្ឌនៃការចូលជាសមាជិក ត្រូវបានគេអនុម័តក្នុងកិច្ចប្រជុំលើកចុងក្រោយជាផ្លូវការរបស់ក្រុមការងារ ។

បន្ទាប់មកឯកសារត្រូវបានគេបង្ហាញអោយ អគ្គក្រុមប្រឹក្សា ឬក៏អោយសន្និសិទ្ធថ្នាក់រដ្ឋមន្ត្រីដើម្បីអនុម័ត ។ ក្នុងករណីដែលក្រុមប្រឹក្សា ឬសន្និសិទ្ធថ្នាក់រដ្ឋមន្ត្រីផ្តល់សេចក្តីយល់ព្រម បណ្តុំនៃលក្ខខ័ណ្ឌចូលជាសមាជិក គឺជាការចែកចាយជាថ្មីនៅក្រោមទំរង់ឯកសារមិនកំនត់ ។ ឯកសារពីរចុងក្រោយត្រូវផ្សព្វផ្សាយ:

1 សេចក្តីសំរេចចិត្តរបស់ក្រុមប្រឹក្សា

2 ប្រូតូកូលនៃការចូលជាសមាជិកពេញសិទ្ធិថ្មីដែលត្រូវបានគេភ្ជាប់ទៅនឹងរបាយការណ៍ ចែងថាប្រទេសដាក់ពាក្យចូលជាសមាជិក WTO ត្រូវបញ្ជូនទៅក្នុងកិច្ចព្រមព្រៀង WTO ។ ប្រូតូកូលនេះរួមមានបញ្ជីហើយក៏ប្រកាសផងដែរពីរបទបញ្ញត្តិចុងក្រោយដែលទាក់ទងទៅនឹងរយៈពេលកំនត់នៃការទទួលយកប្រូតូកូល និងការចូលជាសមាជិក WTO ក្នុងនាមជាសមាជិកភាពពេញសិទ្ធិ ។

**ឆ.សមាជិកភាព**

ក្រោយពីការផ្តល់សេចក្តីយល់ព្រមពីអគ្គក្រុមប្រឹក្សា ឬសន្និសិទ្ធិថ្នាក់រដ្ឋមន្ត្រី បេក្ខជនអាចចុះហត្ថលេខាលើប្រូតូកូលនៃការចូលជាសមាជិកដោយបញ្ញត្តិថា សមាជិកថ្មីព្រមទទួលនូវ បណ្តាលក្ខខ័ណ្ឌនៃការចូលជាសមាជិកដែលត្រូវបានផ្តល់សេចក្តីយល់ព្រមក្រោមការផ្តល់សច្ចាប័នដោយសភាជាតិរបស់ប្រទេសនោះ ។ ជាធម្មតាប្រទេសមួយ ត្រូវទាមទានូវការចុះហត្ថលេខាលើប្រូតូកូល នៃការចូលជាសមាជិកដើម្បីដំណើរការនីតិវិធីដល់ការផ្តល់សច្ចាប័ន ។

# ផ្នែកទី២ កម្ពុជាក្នុងអង្គការពាណិជ្ជកម្មពិភពលោក

## I. លក្ខសម្បត្តិរបស់កម្ពុជាកម្ពុជាក្នុងការចូលជាសមាជិក

ចាប់ពីឆ្នាំ ១៩៩៣ មករដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយពាណិជ្ជកម្ម និងសេដ្ឋកិច្ចថ្មីៗថែមទៀត ដើម្បីធានានូវភាពរឹងប៉ឹង នៃខឿនសេដ្ឋកិច្ចទីផ្សារដែលនៅទន់ខ្សោយ ។ គោលនយោបាយសេដ្ឋកិច្ចថ្មីៗទាំងនោះរួមមាន:

- ការបង្កើត និង ការស្តារឡើងវិញនូវរបបពាណិជ្ជកម្មទ្វេភាគីជាមួយបណ្តាប្រទេសក្នុងតំបន់ និងជាមួយប្រទេសជាដៃគូពាណិជ្ជកម្មសំខាន់ៗ ។
- ការធ្វើសមាហរណកម្មសេដ្ឋកិច្ចទៅក្នុងសេដ្ឋកិច្ចតំបន់អាស៊ាន
- និងការធ្វើសមាហរណកម្មសេដ្ឋកិច្ចទៅក្នុងប្រព័ន្ធពាណិជ្ជកម្មពហុភាគី នៃអង្គការពាណិជកម្មពិភពលោក

តាមរយៈ គោលនយោបាយទាំងនេះកម្ពុជានឹងមានលទ្ធភាពច្រើនថែមទៀត ដើម្បីទាក់ទាញវិនិយោគក្រៅប្រទេសអភិវឌ្ឍន៍ឧស្សាហកម្មសំរាប់នាំចេញ ព្រមទាំងបង្កើតការងារសំរាប់ពលករក្នុងស្រុក និងឈានទៅដល់ការធ្វើអោយមានកំនើនសេដ្ឋកិច្ច។ រហូតមកដល់ពេលនេះ គោលនយោបាយនៃរបបពាណិជ្ជកម្មទ្វេភាគី និងសមាហរណកម្មសេដ្ឋកិច្ច ទៅក្នុងតំបន់ត្រូវបានធ្វើអោយសំរេចជោគជ័យមួយផ្នែកធំរួចមកហើយ។ ដោយឡែកគោលនយោបាយសមាហរណកម្មសេដ្ឋកិច្ចទៅក្នុងប្រព័ន្ធពាណិជ្ជកម្មពហុភាគី ដែលជាផ្នែកមួយសំខាន់នៃគោលនយោបាយសេដ្ឋកិច្ចជាតិត្រូវបានមើលឃើញថា កម្ពុជាត្រូវការពេលវេលា និងការខិតខំប្រឹងប្រែងថែមទៀតដើម្បីធ្វើអោយ គោលនយោបាយសេដ្ឋកិច្ចផ្នែកនេះទទួលបានជោគជ័យ។

**ក.ការកសាងគំរោងការងារច្បាប់**

នៅពេលកម្ពុជាបានចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក WTO កាតព្វកិច្ចមួយដែលកំនត់ដោយសមាជិកភាព WTO សំរាប់កម្ពុជាគឺ ការចូលរួមអោយបានទៀងទាត់ក្នុងកិច្ចដំណើរការ គោលនយោបាយពាណិជ្ជកម្មតាមរយៈយន្តការត្រួតពិនិត្យក្នុងស្រុកជាទៀងទាត់អាចជួយសំរួលកិច្ចដំណើរការនេះបាន។ បញ្ហាមួយចំនួនទាក់ទងទៅនិងសមាជិកភាពរបស់WTO គឺការវាយតំលៃអំពីកម្មវិធីកំណែទំរង់ច្បាប់របស់កម្ពុជា។

**ខ.ការសិក្សាលើការអនុវត្តសុំចូលជាសមាជិក WTO**

ផ្នែមួយនៃការសិក្សាវិភាគនេះ អ្នកជំនាញច្បាប់នៃក្រុមការងារបានធ្វើការដោយផ្ទាល់ជាមួយ មន្ត្រីក្រសួងពាណិជ្ជកម្ម ដើម្បីរៀបចំកម្មវិធីច្បាប់ដើម្បីឆ្លើយតបទៅនឹងតំរូវការរបស់អង្គការពាណិជ្ជកម្មពិភពលោក WTO។ រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានបំពេញការងារជាមួយគ្នាយ៉ាងជិតស្និទ្ធ ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ដើម្បីអនុម័ត និងអនុវត្តន៍ច្បាប់ដែលមានភាពរលូន ស៊ីចង្វាក់ និងទូលំទូលាយនៅកម្ពុជា។ គណៈរដ្ឋមន្ត្រីបានអនុម័តផែនការសកម្មភាពលើសេចក្ដីព្រាងច្បាប់សំរាប់ឆ្នាំ ២០០០ រហូតដល់ឆ្នាំ ២០០៤។ នៅក្នុងការរៀបចំពង្រាងវាយតំលៃ និងអនុម័តច្បាប់ និងលិខិតបទដ្ឋានទាំងនេះ រាជរដ្ឋាភិបាលកម្ពុជាបានកំនត់ថារាល់ក្រសួងទាំងឡាយត្រូវរៀបចំច្បាប់ និងលិខិតបទដ្ឋានទាំងអស់អោយស្របទៅតាមកិច្ចព្រមព្រៀង WTO។

គំរោងជំនួយការបច្ចេកទេសផ្សេងៗខ្លះ កំពុងដំណើរការ និងខ្លះទៀតកំពុងរៀបចំដើម្បីផ្ដល់ការគាំទ្រដល់មន្ត្រីរដ្ឋាភិបាលដើម្បីធ្វើសេចក្ដីព្រាង និងរៀបចំច្បាប់។ ជំនួយការដែលបានផ្ដល់អោយនៅក្នុងការសិក្សាសាកល្បងនេះពាក់ព័ន្ធទៅនឹងការរៀបចំច្បាប់ ឬលិខិតបទដ្ឋាននីមួយៗការពិពរណ៍នាអំពីខ្លឹមសារ និងវិសាលភាពបរិច្ឆេទ អនុម័តតាមផែនការ និងកិច្ចដំណើរការ ព្រមទាំងកិច្ចព្រមព្រៀងរបស់ WTO ដែលបានអនុវត្ត។

**គ.ការកំនត់អាទិភាពសំរាប់កំណែទំរង់ច្បាប់មុនចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក WTO**

ទោះបីជាតំរូវការក្នុងស្រុក ឬតំរូវការចូលជាសមាជិក WTO មានសារៈសំខាន់ក៏ដោយ ក៏កំណែទំរង់គោលនយោបាយពាណិជ្ជកម្មមានសារៈសំខាន់ទាំងកសាងស្ថាប័ន កិច្ចដំណើរការ និងការកំណត់គោលនយោបាយជាក់លាក់។

មានការងារជាច្រើនដែលត្រូវធ្វើ យើងមិនអាចបំពេញ ការងារទាំងអស់នេះបានត្រូវតែមួយទេ ដូច្នេះកត្តាសំខាន់គឺត្រូវកំណត់អាទិភាព។ ច្បាប់មួយចំនួន និងស្ថាប័នខ្លះអាចទុកក្រោយរង់ចាំពេលដែលអាចបំពេញបាន។ ឧទាហរណ៍ ច្បាប់ស្តីពីការប្រកួតប្រជែង អាចទាមទារអោយមានទីភ្នាក់ងារដោយឡែកដែលមានមេធាវី និងអ្នកជំនាញការពូកែ បំពេញការងារជាមួយ។ នៅពេលដែលសេដ្ឋកិច្ចកាន់តែមានភាពបើកចំហរចូលទៅរកពាណិជ្ជកម្មអន្តរជាតិនោះតំរូវការច្បាប់ស្តីពីភាពប្រកួតប្រជែងក៏មិនសូវមានជាប៉ុន្មានដែរ។

**ឃ.ដំណាក់កាលអន្តរកម្មរបស់កម្ពុជាក្នុងសមាជិកភាព WTO**

តើកម្ពុជាបានធ្វើអ្វីខ្លះ ដើម្បីអោយគោលនយោបាយសមារណកម្មសេដ្ឋកិច្ច ទៅក្នុងប្រព័ន្ធពាណិជ្ជកម្មពហុភាគី នៃអង្គការពាណិជ្ជកម្មពិភពលោក បានទទួលជោគជ័យ?

ខុសពីសមាជិកភាព នៃអង្គការអន្តរជាតិដទៃទៀត ដូចជា ធនាគារពិភពលោក មូលនិធិរូបិយប័ណ្ណអន្តរជាតិ **IMF** ការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ប្រទេសសុំចូលជាសមាជិកត្រូវដាក់ពាក្យសុំ និងបង្ហាញអោយសមាជិកនានា នៃអង្គការពាណិជ្ជកម្មពិភពលោក WTO បានឃើញ និងយល់ដឹងអំពីរបបពាណិជ្ជកម្មក្រៅប្រទេសរបស់ខ្លួន ដែលស្របទៅតាមលក្ខខ័ណ្ឌ នៃប្រការចែងនានារបស់កិច្ចព្រមព្រៀងនៃអង្គការពាណិជ្ជកម្មពិភពលោកទាំងអស់ តាមរយៈការចរចារទាំងពីរ គឺការចរចារទ្វេភាគី និងការចរចារពហុភាគីក្នុងការធ្វើសម្បទា។ ការចរចារ ទាំងពីរត្រូវបន្តធ្វើរហូតដល់ការយល់ព្រមពីសមាជិកទាំងអស់។

កម្ពុជាបានដាក់ពាក្យសុំចូលជាសមាជិកអង្គការនេះ នៅខែ តុលា ឆ្នាំ ១៩៩៤ តាមរយៈលិខិតរបស់ក្រសួងពាណិជ្ជកម្មលេខ ០៨៨ MOC ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៩៤ ដោយយោងទៅមាត្រា ៧ នៃកិច្ចព្រមព្រៀងបង្កើតអង្គការពាណិជ្ជកម្មពិភពលោក។ នៅខែ ធ្នូ ឆ្នាំ ១៩៩៤ ក្រុមការងារមួយត្រូវបានបង្កើតឡើងនៅឯលេខាធិការដ្ឋាន អង្គការពាណិជ្ជកម្មពិភពលោកនៅក្រុង ស៊ីណែវ (Geneve) ដើម្បីពិនិត្យការរៀបចំចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោករបស់កម្ពុជា។ ក្រុមការងារនេះមានឈ្មោះថា "ក្រុមការងារកម្ពុជា" Cambodia's Working Party ។

ចាប់តាំងពីពេលនោះមក ការិយាល័យទទួលបន្ទុកកិច្ចការ អង្គការពាណិជ្ជកម្មពិភពលោក ត្រូវបានបង្កើតឡើងនៅក្រសួងពាណិជ្ជកម្ម ព្រមទាំងគណៈកម្មាធិការអន្តរក្រសួង ដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងពាណិជកម្ម ក៏ត្រូវបានបង្កើតអោយមាន ដើម្បីសិក្សាអោយបានស៊ីជុំរៅអំពីលទ្ធភាពនៃការចូលជាសមាជិករបស់កម្ពុជាព្រមទាំងឱកាស និងបញ្ហានានា ដែលអាចកើតមានឡើង និងរៀបចំការចូលជាសមាជិក របស់កម្ពុជានៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក។ ជាលទ្ធផលកម្ពុជាបានបញ្ចប់ដោយជោគជ័យ នូវឯកសារស្តីពីរបបពាណិជ្ជកម្មក្រៅប្រទេស និងបានបញ្ជូនទៅក្រុមការងារកម្ពុជា នៅខែ ឧសភា ឆ្នាំ ១៩៩៩។ ជាបន្តបន្ទាប់កម្ពុជាបានទទួលសំនួរពីប្រទេសជាសមាជិកចំនួន ១៧៩ សំនួរ ដែលស្នើរសុំអោយកម្ពុជា បញ្ជាក់ពីភាពមិនច្បាស់លាស់មួយចំនួន ទៅលើរបបពាណិជ្ជកម្មក្រៅ

ប្រទេសរបស់ខ្លួន។ កម្ពុជាបានបញ្ជូនចំលើយ លើសំនួរទាំងនោះទៅក្រុមការងារកម្ពុជា នៅថ្ងៃទី ០៨ ខែ វិច្ឆិការ ឆ្នាំ ២០០០។

ទន្ទឹមនឹងការបញ្ជូនចំលើយ កម្ពុជាបានធ្វើការចរចារជាច្រើនលើក ជាមួយប្រទេសជាសមាជិកនានា ដូចជា សហរដ្ឋអាមេរិច សហគមន៍អ៊ឺរ៉ុប ជប៉ុន អូស្ត្រាលី ដើម្បីសុំអោយមានការគាំទ្រល្អមគ្រប់គ្រាន់ដើម្បីកម្ពុជាអាចដំណើរការចរចារបស់ខ្លួនបាន។

ជាលទ្ធផលកម្ពុជាទទួលបានជោគជ័យក្នុងការធ្វើអោយយើងអាចរៀបចំការចរចារលើកទីមួយ បាន កាលពីថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១។

## បទបញ្ញត្តិនៃពាណិជ្ជកម្មទូទៅ

ក្នុងចំណោមឯកសារសំខាន់ៗ នៃច្បាប់អាជីវកម្មទូទៅនៅកម្ពុជា ដែលគេបានសន្យានៅក្នុងរបៀងវារៈសម្រាប់អនុម័តច្បាប់ ដើម្បីអនុលោមតាម WTO មានៈ

- ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- ច្បាប់ស្តីពីការបាត់បង់សមត្ថភាពសងបំណុល
- ច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម
- ច្បាប់ស្តីពីភតិសន្យាពាណិជ្ជកម្ម
- ច្បាប់ស្តីពីទីភ្នាក់ងារពាណិជ្ជកម្ម
- ច្បាប់ស្តីពីការបង្កើតតុលាការពាណិជ្ជកម្ម
- ក្រមនីតិវិធីរដ្ឋប្បវេណី
- ក្រមរដ្ឋប្បវេណី
- ក្រមនីតិវិធីព្រហ្មទណ្ឌ
-ក្រមព្រហ្មទណ្ឌ
- ច្បាប់ស្តីពីការប្រកួតប្រជែង
- ច្បាប់ស្តីពីមូលប័ត្រ និងការប្តូរប្រាក់

## ប្រវត្តិនៃការសុំចូលរបស់កម្ពុជា

កម្ពុជាបានដាក់ពាក្យសុំចូលជាសមាជិកអង្គការនេះ នៅខែ តុលា ឆ្នាំ ១៩៩៤ តាមរយៈលិខិតរបស់ក្រសួងពាណិជ្ជកម្មលេខ ០៨៨ MOC ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៩៤ ដោយយោងទៅមាតមាត្រា ៧ នៃកិច្ចព្រមព្រៀងបង្កើតអង្គការពាណិជ្ជកម្មពិភពលោក។ នៅខែ ធ្នូ ឆ្នាំ ១៩៩៤ ក្រុមការងារមួយត្រូវបានបង្កើតឡើងនៅឯលេខាធិការដ្ឋាន អង្គការពាណិជ្ជកម្មពិភពលោកនៅក្រុង ស៊ីណែវ (Geneve) ដើម្បីពិនិត្យការរៀបចំចូលជាសមាជិក

អង្គការពាណិជ្ជកម្មពិភពលោករបស់កម្ពុជា។ ក្រុមការងារនេះមានឈ្មោះថា "ក្រុមការងារកម្ពុជា" Cambodia's Working Party ។

ការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក និងមានការលំបាកយ៉ាងខ្លាំងចំពោះប្រទេសក្រីក្រដូចជាប្រទេសកម្ពុជា។ ដោយហេតុថា ការចរចារតូវធ្វើឡើងលើគ្រប់វិស័យសេដ្ឋកិច្ចទាំងអស់ដែលរួមមានៈ ការធ្វើពាណិជ្ជកម្មផ្នែកទំនិញ សេវាកម្ម វិនិយោគទុន កម្មសិទ្ធបញ្ញា កសិកម្មជាដើម ។

នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០០៣ កម្ពុជាជិតឈានចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក WTO ហើយនៅទីក្រុង *ខេនខាន់* (Cancun) ។ នៅថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ២០០៣ ក្រុមការងារបានរៀបចំកិច្ចប្រជុំមួយដើម្បីកំណត់ពីប្រតិទិនសំរាប់ការចរចារជាលើកចុងក្រោយ លើសមាជិករបស់កម្ពុជាក្នុងអង្គការពាណិជ្ជកម្មពិភពលោក WTO នៅខែ កក្កដា។ ដូច្នេះ គ្រប់ទំរង់ទាំងអស់ត្រូវបានបញ្ចប់ជាស្ថាពរនៅមុនសន្និសិទ្ធិថ្នាក់រដ្ឋមន្ត្រី ដែលប្រព្រឹត្តឡើង នៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០៣ នៅទីក្រុង *ខេនខាន់* (Cancun) ។ ប៉ុន្តែនៅមានកិច្ចការជាច្រើនទៀតសំរាប់បំពេញ នូវកិច្ចចរចារទ្វេរភាគី និងបណ្តាកិច្ចព្រមព្រៀងពហុភាគី ។

ខាងក្រោមនេះ គឺជាកិច្ចការ និងកាលបរិច្ឆេទរបស់កម្ពុជាដែលបានសំរេចបាន ចំពោះសមាជិកភាពក្នុងអង្គការពាណិជ្ជកម្មពិភពលោក WTO:

| | |
|---|---|
| ១ ការដាក់ពាក្យសំចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក WTO នៅថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ១៩៩៤ | |
| ២ ការបង្កើតក្រុមការងារ | នៅថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ១៩៩៤ |
| ៣ ជំនួយការផ្នែកស្មារតី | នៅថ្ងៃទី ២២ ខែ មិថុនាឆ្នាំ ១៩៩៩ |
| ៤ សំនួរ និងចំលើយ | នៅថ្ងៃទី ០៤ ខែ មករាឆ្នាំ ២០០១ |
| ៥ កិច្ចប្រជុំក្រុមការងារ | នៅថ្ងៃទី ២២ ខែ ឧសភាឆ្នាំ ២០០១ |
| | នៅថ្ងៃទី ១៤ ខែ កុម្ភៈឆ្នាំ ២០០២ |
| | នៅថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០២ |
| ៦ ឯកសារផ្សេងៗ | |
| - សំនួរ និងចំលើយបន្ថែម | នៅថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០១ |
| | នៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០២ |
| | នៅថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ២០០៣ |
| - ផ្នែកកសិកម្ម | នៅថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០១ |
| | នៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០២ |
| - ផ្នែកសេវាកម្ម | នៅថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ២០០២-០៣-០៥ |

- គំរោងធ្វើច្បាប់ នៅថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០១

៧ ការចរចារលើផ្នែកទំនិញ

- សំណើរ និងការកំនត់តំលៃ នៅថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០១

- គំរោងបញ្ជីព្រមព្រៀងលើផ្នែកទំនិញ នៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០២

៨ ការចរចារលើផ្នែកសេវាកម្ម

- គំរោងបញ្ជីព្រមព្រៀងលើផ្នែកសេវាកម្ម នៅថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០១

នៅថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០២

៩ គំរោងរបាយការណ៍របស់ក្រុមការងារ

១០. ២០០៤ ប្រទេសកម្ពុជាក្លាយជាសមាជិកទី ១៤៨ របស់អង្គការ WTO

## II. គុណសម្បត្តិ និងគុណវិបត្តិ

### ក. គុណសម្បត្តិ

ក្នុងការចូលជាសមាជិករបស់កម្ពុជា ក៏ដូចជាការចូលរបស់សមាជិករបស់បណ្តាប្រទេសដទៃទៀតដែរ គឺត្រូវផ្អែកលើមាត្រា ៧ នៃកិច្ចព្រមព្រៀងបង្កើត WTO ដែលក្នុងនោះតំរូវអោយបណ្តាប្រទេសសុំចូលធ្វើការចរចារជាមួយសមាជិករបស់ WTO លើបញ្ហាសំខាន់ៗដូចជា ការបើកច្រកទីផ្សារទំនិញ និងសេវាកម្ម ការចរចារលើការលុបបំបាត់ចោលរបាំងមិនមែនពាណិជ្ជកម្ម និងធ្វើករកែទំរង់នៃប្រព័ន្ធច្បាប់ពាណិជ្ជកម្មក្នុងស្រុក អោយស្របជាមួយនឹងកិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោក WTO ។

អង្គការនេះមានគោលការណ៍បីសំខាន់ៗ ដែលតម្រូវអោយសមាជិករបស់ខ្លួនគោរពតាម ។

- គោលការណ៍ទី ១ គឺគោលការណ៍អនុគ្រោះខ្ពស់បំផុតចំពោះផលិតផលរបស់សមាជិក ( Most Favour Nation "MFN") ដែលចែងថា រាល់សម្បទាន ឬការអនុគ្រោះពាណិជ្ជកម្មណាមួយដែលផ្តល់ដោយ សមាជិកណាមួយទៅអោយសមាជិកដទៃទៀត សម្បទាន ឬការអនុគ្រោះពាណិច្ជកម្មនោះ ត្រូវតែផ្តល់ដល់សមាជិក WTO ទាំងអស់ដែរ ។

- គោលការណ៍ទី ២ គឺ គោលការណ៍ប្រព្រឹត្តកម្មជាតិដូចគ្នា ( National Treatment) ដែលគោលការណ៍នេះតម្រូវអោយរដ្ឋាភិបាលជាសមាជិកអនុវត្តនូវច្បាប់ទម្លាប់ក្នុងស្រុកលើផលិតផលក្នុងស្រុក អោយដូចគ្នានឹងការអនុវត្តន៍ចំពោះផលិតផលនាំចូលដូចគ្នាដែរ ។

ឧទាហរណ៍ ដូចជាករវាយពន្ធក្នុងស្រុកទៅលើផលិតផលនាំចូល និងផលិតផលក្នុងស្រុកត្រូវមានកំរិតដូចគ្នា ។

- គោលការណ៍ទី ៣ គឺគោលការណ៍តម្លាភាពដែលគោលការណ៍នេះ តម្រូវអោយរដ្ឋាភិបាលជាសមាជិកបោះពុម្ពផ្សាយនូវបទបញ្ញត្តិច្បាប់គ្រប់គ្រងវិស័យពាណិជ្ជកម្ម និងសេចក្តីសំរេចនានារបស់ខ្លួនដើម្បីធ្វើអោយបានដឹងដល់អ្នកជំនាញ និងជំនួញ និងប្រទេសជសមាជិក WTO ទាំងអស់។

សមាជិករបស់កម្ពុជាក្នុងអង្គការពាណិជ្ជកម្មពិភពលោក WTO នឹងអាចទទួលបាននូវផលប្រយោជន៍សំខាន់ៗ សំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិដូចខាងក្រោមៈ

**១. ការពង្រីកទីផ្សារសំរាប់ផលិតផលកម្ពុជា**

សមាជិកកម្ពុជាក្នុងអង្គការពាណិជ្ជកម្មពិភពលោក WTO នឹងផ្តល់នូវផលប្រយោជន៍ អោយកម្ពុជាមានលទ្ធភាពពង្រីកទីផ្សារសំរាប់ផលិតផលរបស់ខ្លួន ទៅកាន់ទីផ្សានានារបស់សមាជិកអង្គការពាណិជ្ជកម្មពិភពលោក WTO ដែលកមដល់ពេលនេះមានសមាជិកចំនួន ១៤៨ ហើយ។ អង្គការពាណិជ្ជកម្មពិភពលោក WTO គឺជាហ្វូរំសំរាប់ការចរចារលើវិស័យពាណិជ្ជកម្មដោយធ្វើការកាត់បន្ថយពន្ធគយ និងសេវាកម្ម និងករបើកច្រកទីផ្សាលើវិស័យសេវាភាវូបនីកម្មទាំងផ្នែកទំនិញ និងសេវាកម្ម។ រាល់ការកាត់បន្ថយពន្ធ និងសេវាកម្មត្រូវធ្វើឡើងដោយផ្អែកលើគោលការណ៍ ហើយកម្ពុជាយើងអាចទទួលផលប្រយោជន៍អំពី MFN នេះ ហើយកម្ពុជា អាចទទួលផលប្រយោជន៍អំពី MFN នេះ។ នេះមានន័យថា ក្រោយពីកម្ពុជាបានចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក WTO រាល់សម្បទាន និងការសន្យាពាណិជ្ជកម្មទាំងអស់ដែលសមាជិក WTO បានផ្តល់អោយសមាជិកគ្នាគេ នោះត្រូវផ្តល់អោយកម្ពុជាដែរ។ កម្ពុជាអាចនាំចេញផលិតផលរបស់ខ្លួនទៅកាន់ទីផ្សារទាំង ១៤៨ នៃសមាជិកអង្គការពាណិជ្ជកម្មពិភពលោក WTO ជាមួយនឹងពន្ធគយទាប។ យ៉ាងណាមិញ បើកម្ពុជាមិនបានចូលជាសមាជិក ផលិតផលកម្ពុជា និងត្រូវជួបប្រទះពន្ធខ្ពស់ និងរបាំមិនមែនពន្ធ ដូចជា ប្រគូត ការដាក់កំរិតលើស្តង់ដា និងអនាម័យ និងភូត្តគាមអនាម័យដែលមិនសមស្របមួយ ចំនួន ហើយកម្ពុជាយើងគ្មានសិទ្ធិនឹងតវ៉ាឡើយ ព្រោះយើងមិនមែនជាសមាជិករបស់គេ។

**២. ផលប្រយោជន៍ចំពោះឧស្សាហកម្មវាយនភ័ណ្ឌ និងសំលៀកបំពាក់**

ឧស្សាហកម្មដែលរីកចំរើនជាងគេនៅកម្ពុជា គឺឧស្សាហកម្មវាយនភ័ណ្ឌ ព្រោះបណ្តាអ្នកវិនិយោគបានទទួលផលប្រយោជន៍ GSP របស់កម្ពុជា ដែលផ្តល់ដោយបណ្តាប្រទេសជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក WTO ដូចជាសហរដ្ឋអាមេរិច សហគមន៍អឺរ៉ុប កាណាដា និងបណ្តាប្រទេសដទៃទៀត។ ឧស្សាហកម្មវាយនភ័ណ្ឌ និងសំលៀកបំពាក់ជាដង្ហើមសេដ្ឋកិច្ចរបស់កម្ពុជាបច្ចុប្បន្ន។ ដោយការរីកចំរើននៃវិស័យនេះ នៅឆ្នាំ ២០០០ ការនាំចេញសរុបរបស់កម្ពុជា គិតជាទឹកប្រាក់ គឺជាងមួយពាន់លានដុល្លាអាមេរិច។ ឧស្សាហកម្មនេះបានស្រូបយកកម្មករបុគ្គលិក ប្រមាណជាង ២០ ម៉ឺននាក់ គឺមានចំនួនច្រើនបន្ទាប់ពីវិស័យកសិកម្ម។ បច្ចុប្បនេះកិច្ចព្រមព្រៀង ស្តីពីអំពីវាយនភ័ណ្ឌ និងសំលៀកបំពាក់បានអនុញ្ញាតសមាជិករបស់ខ្លួនដាក់ប្រគូតចំពោះទំនិញវាយនភ័ណ្ឌ និងសំលៀកបំពាក់ ប្រសិនបើ

ការនាំនេះមានការប៉ះពាល់ដល់អ្នកផលិតក្នុងស្រុក។ ផលិតផលវាយនភ័ណ្ឌ និងសំលៀកបំពាក់របស់កម្ពុជាយើងក៏បានផលពីការដាក់ប្រគួតនេះដែរ ព្រោះគុណភាពរបសផលិតផលយើងមិនទាន់អាចប្រកួតប្រជែងជាមួយ ផលិតផលនៃបណ្ដាប្រទេសនាំចូលដទៃទៀតបានទេ។ ដូច្នេះ ការបែងចែកប្រគួតបានផ្ដល់លទ្ធភាពអោយផលិតផលវាយនភ័ណ្ឌ និងសំលៀក បំពាក់កម្ពុជាអាចជ្រៀតចូលទីផ្សារសហរដ្ឋអាមេរិច សហគមន៍អឺរ៉ុប កាណាដា បានមួយចំនួន។

### ៣. ការទាក់ទាញវិនិយោគទុនបរទេស

សមាជិកភាពរបស់កម្ពុជា អាចផ្ដល់នូវផលប្រយោជន៍លើការទាក់ទាញវិនិយោគទុនបរទេសចូលកមកកម្ពុជា។ ក្នុងការចូលជាសមាជិក កម្ពុជាត្រូវបង្ខំខ្លួនកែទំរង់ និងធ្វើច្បាប់ថ្មីៗ អោយស្របនឹងកិច្ចព្រនព្រៀងរបស់ អង្គការពាណិជ្ជកម្មពិភពលោក WTO ។ នេះជាសំពាតមួយដែលអាចជំរុញអោយកម្ពុជាយើងសំរេចបាននូវប្រព័ន្ធច្បាប់មួយដែលមានលក្ខណៈល្អប្រសើរសំរាប់គ្រប់គ្រងពាណិជ្ជកម្ម និងវិនិយោគ។ កម្ពុជាមានទីផ្សារតូចដែលមានការលំបាកក្នុងការទាក់ទាញវិនិយោគបរទេសព្រោះចំនួនអ្នកប្រើប្រាស់តិច គឺជាង ១១ លាននាក់ប៉ុណ្ណោះ ហើយប្រាក់ចំនូលក៏ទាប។ ហេតុនេះ អ្នកវិនិយោគទុនបរទេសដែលមក គឺជាអ្នកវិនិយោគទុនដែលផលិតសំរាប់នាំចេញ។ ប្រព័ន្ធច្បាប់ដែលមានលក្ខណៈស្របជាមួយនឹងកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក WTO អាចផ្ដល់នូវទំនុកចិត្តដល់អ្នកវិនិយោគបរទេសបាន។ ការកើនឡើងវិនិយោគទុនបរទេស នឹងបង្កើតនូវការងារជូន ប្រជាជនកម្ពុជាដែលអាចបង្កើននូវជីវភាពរស់នៅរស់នៅរបស់ពួកគេ។

### ៤. ការទទួលសិទ្ធិស្មើគ្នាក្នុងការចរចារ និងដោះស្រាយជំលោះពាណិជ្ជកម្ម

អង្គការពាណិជ្ជកម្មពិភពលោក WTO គឺផ្ដល់នូវហ្វូរំសំរាប់ការចរចារជាបន្តលើវិស័យពាណិជ្ជកម្ម ។ អង្គការនេះផ្ដល់នូវសិទ្ធិស្មើគ្នាដោយមិនប្រកាន់ថាប្រទេសតូច ឬប្រទេសធំឡើយ។ កម្ពុជាយើងអាចមានសិទ្ធិបញ្ចេញសំលេងដើម្បីទាមទារនូវអ្វីដែលខ្លួនយល់ឃើញថាជាផលប្រយោជន៍ ឬប្រឆាំងចំពោះអ្វីដែលប៉ះពាល់ដល់សេដ្ឋកិច្ចរបស់ខ្លួនតាមរយៈការចរចារ។ សំខាន់ជាងនេះ អង្គការនេះផ្ដល់នូវយន្តការដោះស្រាយជំលោះដល់សមាជិករបស់ខ្លួន។ ប្រទេសនីមួយៗ អាចមានសិទ្ធិប្ដឹងទៅអង្គការពាណិជ្ជកម្មពិភពលោក WTO នៅពេលដែលខ្លួនយល់ថាផលប្រយោជន៍របស់ខ្លួននៅក្នុងកិច្ចព្រមព្រៀងត្រូវបានគេរំលោភ។ កម្ពុជាជាប្រទេសតូច ប្រសិនជាកម្ពុជាមិនចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក WTO វាមានការលំបាកក្នុងការដោះស្រាយជំលោះពាណិជ្ជកម្មជាមួយប្រទេសមហាអំណាចធំៗ។ យន្តការដោះស្រាយជំលោះរបស់ WTO ផ្ដល់នូវសិទ្ធិស្មើគ្នាចំពោះសមាជិកទាំងអស់ ។ ដូច្នេះការចូលជាសមាជិកនឹងផ្ដល់នូវភាពកក់ក្ដៅសំរាប់ប្រទេសតូចដូចជាកម្ពុជាយើងសំរាប់ការដោះស្រាយជំលោះពាណិជ្ជកម្ម។ សេចក្ដីសំរេចរបស់ក្រុមអ្នកកាត់ក្ដី WTO នឹងត្រូវប្រតិបត្តិដោយភាគីជំលោះ។

### ៥. ការទទួលបាននូវជំនួយបរទេស

ក្រោមលក្ខខ័ណ្ឌជាប្រទេសក្រីក្រ កម្ពុជាអាចស្នើរសុំជំនួយបច្ចេកទេសនានា ដើម្បីធ្វើការកែទំរង់ សេដ្ឋកិច្ច ច្បាប់ និងការអភិវឌ្ឍន៍ធនធានមនុស្សពាក់ព័ន្ធនឹងកិច្ចព្រមព្រៀង WTO ពីអង្គការពាណិជ្ជកម្មពិភពលោក WTO អង្គការអន្តរជាតិនានា និងប្រទេសជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក WTO ។ ការអភិវឌ្ឍន៍ធនធានមនុស្ស ជាកត្តាសំខាន់ណាស់ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។ ការចូលជាសមាជិករបស់កម្ពុជាក្នុងអង្គការនេះ នឹងអាចសំរេច បាននូវការអភិវឌ្ឍន៍ធនធានមនុស្ស របស់រាជរដ្ឋាភិបាលកម្ពុជាមួយភាគធំ ដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការនៃករ អភិវឌ្ឍន៍ពាណិជ្ជលម្ម និងឧស្សាហកម្មរបស់កម្ពុជាយើង។

ជាសន្និដ្ឋាន ការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក WTO របស់កម្ពុជានឹងនាំមកនវលទ្ធផល ជាច្រើនដល់សេដ្ឋកិច្ចជាតិ។ កម្ពុជាអាចពង្រីកបាននូវទីផ្សារ ការទទួលបាននូវ Quota Free នៅដេមឆ្នាំ ២០០៥ សំរាប់ ផលិតផលវាយនភ័ណ្ឌ និងសំលៀកបំពាក់កម្ពុជា ការទាក់ទាញវិនិយោគទុនបរទេស ការទទួលបាននូវសិទ្ធិ នៃការចរចារពាណិជ្ជកម្ម និងយន្តាការដោះស្រាយជំលោះ នៅក្រោមក្របខ័ណ្ឌនៃអង្គការពាណិជ្ជកម្មពិភពលោក WTO។ ការសំរេចរបស់រដ្ឋាភិបាលក្នុងការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក WTO គឺជានយោបាយ ដ៏ត្រឹមត្រូវ ដែលអាចជាក្តីសង្ឃឹមនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ហើយអាចបង្កើនការងារលើកស្ទួយកំរិតជីវភាពរបស់ ប្រជារាស្ត្រខ្មែរ។

### ខ. គុណវិបត្តិ

#### ១. ផលប៉ះពាល់នៃតារាងពន្ធគយ

នៅពេលកម្ពុជាធ្វើសំណើរសុំចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក WTO កម្ពុជាទទួលបានសំនួរស្តី ពីអត្រាអតិបរមា ហើយចាំបាច់ត្រូវតែធ្វើការចរចារ។ អត្រាដែលបានចរចារទាំងនេះអាចមានប្រសិទ្ធភាពចងភ្ជាប់ កម្ពុជាមិនអោយធ្វើការបង្កើនពន្ធ ក្រោយមកទៀត។ ទស្សនៈមួយគឺថានៅដំណាក់កាលនេះកម្ពុជាត្រូវតែស្វែងរកការ ចរចារពីកំរិតដែលអាចអនុញ្ញាតបានខ្ពស់បំផុត។ ទង្វើនេះផ្តល់អោយកម្ពុជា នូវសិទ្ធិសេរីភាពធ្វើសេចក្តីសំរេចពីកំរិត អត្រាពន្ធគយ។ តែទោះជាយ៉ាងណាក៏ដោយ ការចងអត្រាកំនត់ទាបដែលបានកំណត់ទាបអាចនិយាយបានថាស្មើ ឬទាបបំផុតទៅនិងអត្រាដែលអនុវត្តបច្ចុប្បន្ន។ អត្រាទាបដែលមានប្រសិទ្ធិភាពចងភ្ជាប់ បានកំណត់នូវស្ថេរភាពភាព គួរអោយជឿជាក់នៅក្នុងក្របខ័ណ្ឌនយោបាយពាណិជ្ជកម្មរបស់ប្រទេស។ អ្វីដែលជាកត្តាសំខាន់សំរាប់កម្ពុជា គឺការ រៀបចំបង្កើតការកែច្នៃ និងពតិមានដែលមានដើម្បីវិនិច្ឆ័យថា រចនាសម្ព័ន្ធពន្ធគយបែបណាដែលល្អសំរាប់កម្ពុជា។

គោលការណ៍ជាមូលដ្ឋាន GATT អាចមានភាពខុសគ្នាខ្លះនៅក្នុងទិដ្ឋភាពមួយចំនួនសំរាប់សមាជិកនៃបណ្តា ប្រទេសកំពុងអភិវឌ្ឍន៍ និងសមាជិកនៃបណ្តាប្រទេសអភិវឌ្ឍ។ ដូច្នេះ បណ្តាប្រទេសអភិវឌ្ឍមិនអាចរំពឹងទៅលើ ការជួយបំពេញអោយគ្នាទៅវិញទៅមក លើការសន្យាបន្ថយអត្រាពន្ធគយនោះទេ ហើយតាមប្រយោជន៍ស្តីពីការជួយ គ្នា អាចផ្តល់កិច្ចប្រព្រត្តកម្មដែលផ្តល់ភាពអនុគ្រោះច្រើនជាងអត្រា MFN ទៅទៀត។ បទបញ្ញាតិផ្សេងៗ សំរាប់

បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសជឿនលឿនបានអនុញ្ញាតិអោយបណ្តាប្រទេសជាសមាជិកទាំងឡាយរក្សាវិធានការណ៍ជំនួយលើរយៈពេលយូរអង្វែងបាន។ នេះជាចំរើសផងដែរស្តីពីការណែនាំលើការគ្រប់គ្រងបរិមាណសំរាប់មូលហេតុតុល្យភាពនៃការទូទាត់។ ការរួមចំណែកនៃបទបញ្ញត្តិទាំងនេះ ទៅលើគោលនយោបាយរបស់បណ្តាប្រទេសក្រីក្រ គឺជាបញ្ហាមួយ។ ក្រៅពីជាគោលការណ៍ណែនាំសំរាប់គោលនយោបាយល្អ បទបញ្ញត្តិនេះ ត្រូវបានចាត់ទុកថាមានភាពជាក់ស្តែងជាង ព្រោះធ្វើអោយប្រទេសក្រីក្រអាចងាកចេញពីគោលនយោបាយមិនល្អបាន។

នៅពេលចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក WTO សមាជិកភាពអាចមានវិធីមួយដែលពង្រឹងរាល់កំណែទំរង់យើងចង់សំរេចអោយស្របទៅតាមវិធានអង្គការពាណិជ្ជកម្មពិភពលោក WTO នោះមិនអាចធានាលទ្ធផលនៃគោលនយោបាយដែលល្អបំផុតសំរាប់ប្រទេសកម្ពុជាបាន។ ឧទាហរណ៍ បទបញ្ញត្តិអង្គការពាណិជ្ជកម្មពិភពលោក WTO អនុញ្ញាតអោយមានចំណាត់ការលើការលក់បង្ខូចថ្លៃ និងការលក់ដោយមានការប៉ះប៉ូវ។ បទបញ្ញត្តិទាំងនេះ ជារឿយៗអាចចាត់ទុកថាជាលេសសំរាប់ការការពារការនិយម និងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ មួយចំនួនធំ។ ជំនួយដែលប្រទេសកម្ពុជាទទួលបានជាមួយការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក WTO ចាំបាច់ត្រូវបំពេញបន្ថែមជាមួយជំនួយសំរាប់ការកសាងសមត្ថភាព ក្នុងការអនុវត្តន៍បច្ចេកទេស និងគោលការណ៍សំរាប់វាយតំលៃគោលនយោបាយដោយផ្អែកលើលក្ខណៈសម្បត្តិ។

ការកាត់បន្ថយពន្ធគយ គឺជាបញ្ហាមួយដ៏សំខាន់សំរាប់កម្ពុជា ពីព្រោះចំណូលថវិការជាតិភាគច្រើន គឺបានមកពីការប្រមូលពន្ធ។ តារាងពន្ធគយត្រូវបានកែសំរួលឡើងវិញនៅក្នុងខែ មេសា ឆ្នាំ ២០០១ ។ អត្រាពន្ធគយដែលខ្ពស់ត្រូវបានកាត់បន្ថយពី ១២០% មកត្រឹម ៣៥% ។ ក្រៅពីនេះប្រព័ន្ធពន្ធគយក៏ត្រូវបានកាត់បន្ថយកំរិតពន្ធពី ១២ ចុះមកត្រឹម ៤ កាំផងដែរ។

ភារកិច្ចក្នុងការគ្រប់គ្រងមានបញ្ហាស្មុកស្មាញ ដោយសារៈ

- មានការលើកលែងពន្ធជាច្រើន និងតំរូវការអនុញ្ញាតអោយអ្នកនាំចេញអាចទិញវត្ថុធាតុដើមនៅលើទីផ្សារនិងពិភពលោកដែលមានតំលៃទាប។
- តំរូវការស្តីពីវិធានការណ៍នៃប្រភពទំនិញដែលបានកំណត់ដោយដៃគូពាណិជ្ជកម្ម
- កិច្ចព្រមព្រៀងអនុគ្រោះផ្អែកពាណិជ្ជកម្ម
- ធនធានមានកំណត់
- ប្រាក់ខែទាប
- គ្មានស្វ័យប្រវត្តិកម្ម
- ការទទួលខុសត្រូវមិនច្បាស់លាស់
- ភារកិច្ចជាន់គ្នា

ដើម្បីពិនិត្យដោះស្រាយកិច្ចការធនធានមានកំណត់ទាំងនេះ និងទទួលរងគ្រោះដោយសារការងារជាន់គ្នា:

- ប្រាក់ខែមន្ត្រីរាជការទាប

- គ្មានសេវាកម្មស្វ័យប្រវត្តិ ហើយសម្ភារទានគ្រឿងបរិក្ខាប្រើប្រាស់ជារូបវន្តបុគ្គលក៏អន់ថយ

- ការគ្រប់គ្រង និងការទទួលខុសត្រូវមិនបានកំណត់អោយបានច្បាស់លាស់រវាង PIS ជាមួយភ្នាក់ងារដឹកជញ្ជូន

- នាយកដ្ឋានគយ និងរដ្ឋករធ្វើការជាមួយភ្នាក់ងារផ្សេងៗមួយចំនួននៅតាមព្រំដែន ដែលមានការទទួលខុសត្រូវជាន់គ្នា និងភ័នច្រឡំ

- សមត្ថភាពដើម្បីឈានទៅរកប្រព័ន្ធពិនិត្យការគ្រប់គ្រងអានិភ័យ ត្រូវបានរារាំងដោយការខ្វះខាតពតិមាន និងប្រព័ន្ធគ្រប់គ្រងទិន្នន័យ ហើយមិនមានការលើកទឹកចិត្ត ដើម្បីឈានទៅរកការគ្រប់គ្រងអានិភ័យ ព្រោះគិតថានេះជាកាលានុវត្តន៍ភាព ដែលអាចរកប្រាក់បន្ថែមក្រៅបាននៅពេលធ្វើការត្រួតពិនិត្យរាល់ការដឹកជញ្ជូនទំនិញ បន្ថែមទៅលើប្រាក់បៀវត្សទាប។

កាលៈទេសៈទាំងនេះជុំរុញអោយមានការព្រួយបារម្ភទៅលើការកែសំរួលពាណិជ្ជកម្ម តាមរបាយការណ៍បានអោយដឹងថា ការបង់ប្រាក់ក្រៅផ្លូវការមានខ្ពស់ ហើយការប្រមូលចំណូលរបស់រដ្ឋាភិបាលក៏មានការរាំងស្ទះ ដោយសាររត់ពន្ធ និងការគេចពន្ធ។

ការសំរួលផ្នែកពាណិជ្ជកម្មមិនមែនកើនឡើងតែនៅតាមព្រំដែនទេ។ ពាណិជ្ជកម្មអន្តរជាតិក៏អាស្រ័យទៅលើការចរចារទំនិញក្នុងប្រទេសដោយសេរីផងដែរ។ ដូចនេះការសំរួលផ្នែកពាណិជ្ជកម្មនៅក្នុងប្រទេសកម្ពុជាទាមទារអោយឧបសគ្គដែលរារាំងដល់ការចរចារទំនិញនៅក្នុងរូបភាពដែលមានហេដ្ឋារចនាសម្ព័ន្ធអន់ថយ និងមានរបាំងដែលអាចកើតឡើងនៅក្នុងសណ្ឋាន និងការគិតថ្លៃឈ្នួលលើការដឹកជញ្ជូនឆ្លងកាត់ និងភាពផ្តាច់មុខនៃការស្វែងរកទីផ្សារក្នុងស្រុក។

### ២. បញ្ហាប្រកួតប្រជែងផលិតផលក្នុងស្រុកលើទីផ្សារអន្តរជាតិ

បញ្ហានេះ គឺជារបាំងពាណិជ្ជកម្មក្រៅប្រទេស។ របាំងពាណិជ្ជកម្មក្រៅប្រទេស ពិនិត្យមើលទំនិញនាំចេញសំខាន់ៗចំនួន ៥០ មុខរបស់កម្ពុជា ដែលផលិតផលសំខាន់ៗមាន សំលៀកបំពាក់ (៧៤ភាគរយ) ស្បែកជើង (៥ភាគរយ) ផលិតផលឈើ ( ៤ភាគរយ) និងផលិតផលកៅស៊ូ (៣ភាគរយ) ។ ទីផ្សារសំខាន់សំរាប់សំលៀកបំពាក់គឺទីផ្សារសហរដ្ឋអាមេរិច និងសហគមន៍អឺរ៉ុប។ ក្នុងឆ្នាំ ២000 កម្ពុជាបាននាំចេញសំលៀកបំពាក់ទៅសហរដ្ឋអាមេរិចចំនួន ៧៦ ភាគរយ និងទៅលើទីផ្សាអឺរ៉ុបចំនួន ២៣ ភាគរយ។ ស្បែកជើងភាគច្រើនត្រូវបានគេនាំចេញទៅកាន់ទីផ្សាអឺរ៉ុប (៦0 ភាគរយ) និងទៅជប៉ុន (៣៥ ភាគរយ) ។

ក្រុមការងារនៃការសិក្សាវិភាគបានរៀបចំ និងចាប់ផ្តើមធ្វើការស្ទាប់ស្ទង់មតិជាមួយក្រុមហ៊ុននាំចេញជាង ១០០ ក្រុមហ៊ុន។ ក្រុមហ៊ុនទាំងនេះមានសកម្មភាពក្នុងវិស័យកាត់ដេរ ស្បែកជើង ការធ្វើពាណិជ្ជកម្មលក់ដុំ និងរាយ រោងចក្រកែច្នៃឈើ ជលផល កែច្នៃផលិតផលកសិកម្ម និងឈើមូល។ ក្រុមហ៊ុនកាត់ដេរបានលើកឡើងថា ប្រគួតអត្រាពន្ធគយ និងតំរូវការកំលាំងពលកម្ម គឺជាឧបសគ្គដ៏ចំបងក្នុងការនាំទៅកាន់ទីផ្សារអាមេរិច។ យោបល់អំពីទីផ្សាអឺរ៉ុបមានប្រហាក់ប្រហែលគ្នា មានន័យថា ទំនិញមួយចំនួនធំមិនអាចទទួលបាននូវការលើលែងពន្ធ ហើយត្រូវចូលទៅតាមអាត្រា MFN ។ ក្រុមហ៊ុនផលិតស្បែកជើង បានបង្កើតឡើងជាបឋមតាមរយៈការវិនិយោគរបស់ក្រុមហ៊ុនតៃវ៉ាន់។ ផលិតផលស្បែកជើងភាគច្រើនក៏នាំចេញទៅកាន់ទីផ្សារអឺរ៉ុប និងកាណាដា កំរនឹងបាននាំចេញទៅកាន់ទីផ្សារអាមេរិចណាស់។ ជាក់ស្តែងមានការលំបាកក្នុងការរករូបធាតុដើម ហើយតម្រូវការអោយប្រើប្រាស់រូបធាតុដើមក្នុងស្រុកចំនួន ៤០ ភាគរយ បង្កើតបានជាការលំបាកដល់អ្នកផលិត។ តារាងពន្ធគយហាក់ដូចមិនជាឧបសគ្គដ៏សំខាន់សំរាប់អ្នកនាំចេញ និងក្រុមហ៊ុនដែលធ្វើការនាំចេញទៅកាន់ប្រទេសជប៉ុន ពីការកំណត់អាត្រាពន្ធគយទៅកាន់ប្រទេសទាំងនោះ ហាក់ដូចជាគ្មានបញ្ហាឡើយ។ ស្តង់ដានៃកំលាំងពលកម្មចំពោះទំនិញនាំទៅកាន់អឺរ៉ុបអាចជាបញ្ហាមួយ។ ប្រជាជនកម្ពុជាដែលមានកម្មសិទ្ធិភាព និងគ្រប់គ្រងនាំចេញទំនិញផ្សេងទៀតហាក់ដូចជាមានច្រើនជាង។ លទ្ធផលនៃការស្ទាប់ស្ទង់មតិជាមួយក្រុមហ៊ុនទាំងនេះ មិនបង្ហាញអោយឃើញនូវកំរិតមតិអំពីរបាំងពាណិជ្ជកម្មដូចគ្នាទេ។

ទោះបីជាកម្ពុជាបានទទួលការអនុញ្ញាតលើកលែងពន្ធលើទំនិញជាង ៦០០០ មុខ តាម USGSP ក៏ដោយ ក៏ចំនុចដែលកម្ពុជាអាចប្រគួតប្រជែងដោយមានប្រសិទ្ធភាពបាននោះ គឺទាក់ទងទៅនឹងគុណភាពផលិតផលសំលៀកបំពាក់ ដែលត្រូវបានចាត់ទុកថាជាទំនិញដែលមានវេទយិតភាព និងអាចត្រូវលើកលែងពីប្រព័ន្ធ GSP ។ អាត្រា MFN អនុវត្តទៅលើប្រទេសកម្ពុជា ហើយមានទំនិញសំលៀកបំពាក់ចំនួន ១២ ប្រភេទ ដែលស្ថិតនៅក្រោមការកំណត់ប្រគួត ។ ដូចនេះទោះជាកត្តាជាក់ស្តែងណា ប្រទេសកម្ពុជា គឺជាប្រទេសក្រីក្រមួយក៏ដោយក៏ការបង់ពន្ធលើទំនិញទៅសហរដ្ឋអាមេរិចមានជាមធ្យម គឺ ១៧ ភាគរយ។ នៅសហគមន៍អឺរ៉ុបប្រទេសកម្ពុជាមិនស្ថិតនៅក្រោមលក្ខខ័ណ្ឌប្រគួតទេ និងអាចរួចផុតពីវាយនភ័ណ្ឌដែលជឿនលឿនទេ ហើយតំរូវការស្តីពីវិធាននៃប្រភពទំនិញបានហាមឃាត់ពីការនាំចូលវាយនភ័ណ្ឌពីប្រទេសផ្សេង។ ដូច្នេះអាត្រាពន្ធលើទំនិញនាំចេញអឺរ៉ុបមានជាមធ្យម គឺ ៨.៨ភាគរយ។ ការអនុវត្តនៃការដាក់កំហិតនេះមាននៅក្នុងការសិក្សាដែលស្តីអំពីការសិក្សាផ្នែកវាយនភ័ណ្ឌ ផ្នែកគយក្នុងជំពូក ៥ នៃទស្សនះវិស័យជារួមនេះ។

ការទទួលបានភាពអនុគ្រោះពន្ធ ហាក់ដូចជាផ្ទរដ៏មានតំលៃមួយ ប៉ុន្តែវាមានការខាតបង់របស់វាដូចជា: ឧបសគ្គការិយាល័យធិបតេយ្យមួយចំនួនដែលបានកំណត់ជាការដាក់កំហិត បណ្តាលមកពីតំរូវការក្នុងការចូលទៅកាន់ទីផ្សារ។ ឧទាហរណ៏ រដ្ឋបាលនៅតាមព្រំដែនកាន់តែមានភាពស្មុគស្មាញថែមទៀត ដោយមានតំរូវការអោយអនុវត្តវិធានផ្សេងៗស្តីពីប្រភពដើមទំនិញ។ ទោះបីជាច្បាប់ស្តីពីការងារកម្ពុជាឆ្លើយតបតែទៅនឹងតំរូវការទីផ្សារកំលាំងពលកម្មក្នុង

ស្រុកក៏ដោយ តែការគ្រប់គ្រងលក្ខខ័ណ្ឌនៃកំលាំងពលកម្ម សំរាប់វិស័យកាត់ដេរត្រូវតែភ្ជាប់ទៅនឹងតំរូវការស្តង់ដារពលកម្មរបស់ទីផ្សារអាមេរិច និងអឺរ៉ុបផងដែរ។ ការពង្រីកប្រគួតរបស់អាមេរិចផ្សារដោយផ្ទាល់ទៅនឹងការអនុវត្តន៍អោយ បានទូលាយតាមស្តងដាការងារ។ ឯលក្ខខ័ណ្ឌ GPS ក៏មានចែងពីលក្ខខ័ណ្ឌការងារ និងបរិស្ថានផងដែរ។ ប្រាក់ឈ្នួល អប្បបរមា គឺជាប្រាក់ផ្ទេរទៅអោយកម្មករដែលកំពុងបំរើការងារ។ នេះជាបញ្ហាវិជ្ជមានរបស់ពួកគេ ប៉ុន្តែអវិជ្ជមាន សំរាប់ប្រជាជនផ្សេងទៀតដែលមិនអាចរកការងារធ្វើបាន។ ការកំណត់អោយបង់ប្រាក់ឈ្នួលមួយជាពីរចំពោះ ការងារវេនពេលយប់ ហាក់ដូចជាមិនបានជួយនរណាម្នាក់ឡើយ ពីព្រោះវាបង្កើនចំនាយផលិតកម្មនៅកម្ពុជា និងមិន បានបង្កើននូវកាលានុវត្តន៍ភាពសំរាប់ប្រជាជនដែលចង់រកការងារធ្វើ។

ទោះបីកំរិតផលិតភាពកម្ពុជា មានខ្ពស់ក៏ដោយក៏ការចំណាយនៅតែមានខ្ពស់ដែរ បើប្រៀបទៅនឹងបណ្តាប្រទេសប្រកួតប្រជែងផ្សេងទៀត។ បណ្តាប្រទេសប្រកួតប្រជែងមួយចំនួនដូចជា ប្រទេសវៀតណាមកំពុងទទួលបាន MFN ដែរ។ ការដាក់កំហិតប្រគួតលើការនាំចេញពីបណ្តាប្រទេសផ្សេងៗ ចូលទៅទីផ្សារអាមេរិច និងអឺរ៉ុប គ្រោងនឹងលុបចោលនៅឆ្នាំ ២០០៥ តាមកិច្ចព្រមព្រៀងស្តីពីវាយនភ័ណ្ឌ និងសំលៀកបំពាក់។

## III. ផលិតផលកម្ពុជានាំចេញ

### ក.កសិកម្មអាជីវកម្មទូទៅ

ប្រទេសកម្ពុជាមានធនធានកសិកម្មជាច្រើន ហើយមានសក្តានុពលច្រើន សម្រាប់ប្រែក្លាយសម្បត្តិ កសិកម្មទាំងនោះទៅជាអាជីវកម្មនាំចេញប្រកបដោយជោគជ័យ។ ចំពោះផលិតផលសំខាន់ៗមួយចំនួន ការបាត់បង់គុណភាពរបស់ទំនិញកសិកម្ម តាមរយៈការរត់ពន្ធ គឺជាបញ្ហាចំពោះមុខដ៏ធំបំផុត។ ការចំណាយ ខ្ពស់នៅក្នុងប្រទេសហេដ្ឋារចនាសម្ព័ន្ធមិនល្អ អប្រសិទ្ធភាពផ្នែករដ្ឋបាល ក៏ដូចជាកង្វះការវិនិយោគ លើសមត្ថភាពកែច្នៃទាំងអស់នេះមិនបង្កលក្ខណៈល្អចំពោះការធ្វើអាជីកម្មតាមផ្លូវការឡើយ។ កសិករ និង អ្នកលក់ដុំច្រើនតែជ្រើសរើសយកជម្រើសងាយបំផុត គឺលក់ទៅឱ្យពាណិជ្ជករមកពីប្រទេសជិតខាងនៃ ប្រទេសកម្ពុជា ដែលមានលទ្ធភាពរ៉ាប់រងចំណាយក្រៅផ្លូវការ ក្នុងការដឹកកជញ្ជូនទំនិញចេញពីប្រទេសកម្ពុជាសំរាប់កែច្នៃ និងលក់បន្ត។ កំនែទំរង់ច្បាប់ដែលទាមទារដោយ សមាជិកភាពក្នុង WTO ព្រមទាំង លទ្ធភាពចូលទៅកាន់ទីផ្សារដែលមានភាពអនុគ្រោះពាណិជ្ជកម្មអាចជួយបានក្នុងករណីនេះ។ ប៉ុន្តែ បរិយាកាសពាណិជ្ជកម្មសាកលអាចកែលំអបានជាកំរិតៗប៉ុណ្ណោះ ដោយយោងតាមបទបញ្ញត្តិនានារបស់ WTO។ គេត្រូវតែយល់ដឹងជាចាំបាច់ អំពីរបាំងពន្ធគយដ៏ខ្ពស់ របបកូតាក៏ស្មុគស្មាញ និងការរំរូវឱ្យមានសុវត្ថិភាពស្បៀងអាហារ ដើម្បីចាប់យកឧត្តមភាពនៃឱកាសថ្មីៗ។ ក្រុមកសិអាជីវកម្មគប្បីពិនិត្យមើលឱ្យបានហ្មត់ចត់នូវសក្តានុពលនៃកិច្ចប្រជុំនៅទីក្រុង ដូហា (Doha) ដើម្បីកែលំអលក្ខខ័ណ្ឌនានា ក្នុងពេលអនាគត។

### ខ. អង្ករ

កម្ពុជាមានឱកាសតិចតួចណាស់ ក្នុងការវិលត្រលប់ទៅកាន់ថានៈជាប្រទេសនាំចេញអង្ករដ៏ធំមួយ។ បរិមាណស្រូវជាច្រើនត្រូវបានគេរត់ពន្ធទៅកាន់ប្រទេសវៀតណាម ដើម្បីយកទៅកិន រួចហើយ នាំចេញបន្ត។

បើមានការវិនិយោគបន្ថែមទៀតលើម៉ាស៊ីនកិនស្រូវដែលមានលក្ខណទំនើប នោះកម្ពុជានឹងអាច ផ្គត់ផ្គង់អង្ករដែលមានគុណភាពល្អពិសេសទៅកាន់ទីផ្សារអន្តរជាតិ។

### គ. គ្រាប់ស្វាយចន្ទី

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ការរីកចំរើនដ៏ធំបំផុតនៅលើទីផ្សារគ្រាប់ស្វាយចន្ទី នៅក្នុងពិភពលោក គឺការលេចមុខនៃប្រទេស វៀតណាម ដែលបានក្លាយជាប្រទេសផលិត និងនាំចេញគ្រាប់ ស្វាយចន្ទីធំជាងគេ។ កសិផលស្វាយចន្ទីរបស់កម្ពុជាមួយផ្នែកធំត្រូវបានគេទិញដោយឱ្យប្រាក់ផ្ទាល់ដៃ និងដឹកជញ្ជូនក្រៅផ្លូវការ ឬរត់ពន្ធឆ្លងដែនទៅកាន់ប្រទេសវៀតណាម។ ការគួបផ្សំគ្នានៃការចំណាយខ្ពស់នៅក្នុងប្រទេស និងការទាមទារឱ្យមានការបង់ប្រាក់ក្រៅផ្លូវការ នៅក្នុងការដឹកជញ្ជូនផលិតផលឆ្លងកាត់ផែនានា ជាមូលហេតុធ្វើឱ្យផលិតកម្មគ្រាប់ស្វាយចន្ទីនៅកម្ពុជាជួបការលំបាក និងគ្មានលទ្ធភាពប្រគួតប្រជែងខ្ពស់។

### ឃ. បសុសត្វ

មានការសិក្សា និងការពិសោធផ្សេងៗបញ្ជាក់ថា ប្រទេសកម្ពុជាមានឱកាសយ៉ាងច្រើនក្នុងការនាំចេញបសុសត្វ ដូចជា គោ ក្របី ជ្រូក និង បសុបក្សី។ បច្ចុប្បន្ននេះ ការធ្វើពាណិជ្ជកម្មគោ ក្របី ច្រើនប្រព្រឹត្តទៅតាមរយៈការរត់ពន្ធ។ ប្រសិនបើ បំប៉នចំណីអាហារឱ្យបានត្រឹមត្រូវ គេអាចលក់គោ ក្របី កម្ពុជា ទៅកាន់ទីផ្សារក្នុងតំបន់ ឬមួយប្រហែលជាអាចលក់ទៅឱ្យទីផ្សារមជ្ឈឹមបូពា ដែលកំពុងតែមាន តម្រូវការកើនឡើងផងដែរ។ ការធ្វើអាជីវកម្មទៅលើវិស័យបសុសត្វ ក៏តម្រូវឱ្យមានការ កែលំអរ លទ្ធភាព ផលិតចំណីសត្វ ដែលមានលក្ខណប្រគួតប្រជែងដែរ។

### ង.ផ្លែស្វាយ

កសិករកម្ពុជាដាំផ្លែឈើដែលមានាគុណភាពខ្ពស់ជាច្រើនប្រភេទ ហើយផ្លែឈើទាំងនោះមួយចំនួន មានតម្រូវការខ្ពស់នៅក្នុងទីផ្សារនៃប្រទេសរីកចំរើន។ តម្រូវការផ្លែស្វាយបានកើនឡើងយ៉ាងច្រើន នៅក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ ដោយពាណិជ្ជកម្មពិភពលោកកើនឡើងទ្វេមួយជាពីរ។ នៅកម្ពុជា គេគួររៀបចំការដាំស្វាយឱ្យបានប្រសើរជាងមុន ដែលពុំមែនសំរាប់តែការនាំចេញតែប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវ ឆ្លើយតបនឹងតំរូវការក្នុងប្រទេស ដោយរាប់ទាំងតំរូវការរបស់វិស័យទេសចរណ៍ផងដែរ។

### ច.ប្រេងរុក្ខជាតិ

ប្រទេសកម្ពុជាបាននាំចូលប្រេងរុក្ខជាតិជាច្រើនប្រភេទ ប៉ុន្តែកម្ពុជាមានបទពិសោធក្នុងការនាំចេញ ដូងប្រេង (Palm Oil)។ គេបាននាំចេញគ្រាប់ធញ្ញជាតិផ្តល់ប្រេងពីប្រទេសកម្ពុជា ប៉ុន្តែតាមច្រកមិនផ្លូវការ ដើម្បីបំពេញឱ្យសមត្ថភាពកែច្នៃធំៗ ជាច្រើននៅបណ្តាប្រទេសជិតខាង។ ប្រទេសកម្ពុជា មានឱកាសសំរាប់នាំចេញប្រេងដូងបន្ថែមទៀត និងផលិតដើម្បីជំនួសប្រេងរុក្ខជាតិនាំចូលមួយចំនួន ប្រសិនបើគេអាចកាត់បន្ថយចំណាយក្នុងដំណើរការផលិតក្នុងប្រទេសបាន។

**ឆ. ស្រាទឹកត្នោត**

ស្រាទឹកត្នោត គឺជាផលិតផលមួយក្នុងចំណោមផលិតផលជាច្រើន ដែលអាចផលិតបានពីដើមត្នោត។ ក្រុមហ៊ុនមួយ ដែលមានទីតាំងស្ថិតនៅជិតទីក្រុងភ្នំពេញ កំពុងផលិតដំណាប់ផ្លែឈើ ទឹកខ្មេះ មួក និងកន្ត្រក ព្រមទាំងស្រាមួយចំនួន និងភេសជ្ជៈចំរុះនានា ដែលផលិតពីផលិតផល ផ្សេងៗនៃដើមត្នោត។ ភេសជ្ជៈដែលមានជាតិស្រវឹងរបស់ក្រុមហ៊ុននេះ គឺស្រាទឹកត្នោតដែលមានគុណភាពពីរបែប (មានជាតិស្រវឹងក៏រិត ៨% និង ១០%) ស្រាទឹកត្នោតលាយម្នាស់ និងស្រាទឹកត្នោតមានរសជាតិខ្ញី។ ការតក់ប្រាក់បន្ទុក រដ្ឋបាលមិនផ្លូវការ និងកង្វះខាតផ្នែកហេដ្ឋារចនាសម្ព័ន្ធ នៅកម្ពុជាធ្វើឱ្យ ប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សមត្ថភាពប្រគួតប្រជែង។

**ជ. កៅស៊ូ**

បន្ទាប់ពីសំលៀកបំពាក់ និងស្បែកជើង កៅស៊ូធ្លាប់ជាផលិតផលនាំចេញ ដែលមានសារៈសំខាន់បំផុតរបស់កម្ពុជា។ ជាទូទៅ គុណភាពនៃកម្ពុជាមានក៏រិតខ្ពស់ប៉ុន្តែកម្ពុជាពុំសូវបានលក់កៅស៊ូទៅកាន់ អតិថិជននៅបរទេសដោយផ្ទាល់ឡើយ ហើយគេតែងលក់ក្នុងតំលៃ ១៥-២០% ទាបជាងតំលៃ នៅក្នុងទីផ្សារពិភពលោក។ ឧស្សាហកម្មកៅស៊ូកម្ពុជាមួយភាគធំគ្រប់គ្រងដោយរដ្ឋ។ វិធានរបស់ WTO និង លក្ខខ័ណ្ឌនៃការចូលទៅកាន់ទីផ្សារមានសារៈប្រយោជន៍តិចតួចប៉ុណ្ណោះ លុះត្រាតែក្រុមហ៊ុនកៅស៊ូកម្ពុជា ផលិតកៅស៊ូរាមគុណភាពជាអន្តរជាតិ។

**ឈ. ត្រី**

ប្រទេសកម្ពុជាមានឱកាស និងអាចមានសក្តានុពលយ៉ាងច្រើន ក្នុងការធ្វើអាជីវកម្មលើធនធានត្រី របស់ខ្លួននៅក្នុងទីផ្សារនាំចេញ។ តំរូវការចំពោះត្រីដែលមានគុណភាពខ្ពស់ និងផលិតផល ត្រីកំពុងកើនឡើងនៅក្នុងពិភពលោកក្នុងអំឡុងពេលដែលការផ្គត់ផ្គង់មានក៏រិត។ គេបើកទូលាយទីផ្សារយ៉ាងច្រើន ប៉ុន្តែកម្ពុជា ចាំបាច់ជំនះឧបសគ្គនានាដូចជាបទដ្ឋានសុវត្ថិភាពស្បៀងអាហារចំពោះអ្នកប្រើប្រាស់ ការដាក់ផ្លាកសញ្ញាការផលិតដែលមាននិរន្តភាព និងការប្រើប្រាស់ឧបត្ថមធនជាទូទៅ ដើម្បីឱ្យខ្លួនអាចប្រមើល មើលកាន់តែច្បាស់លាស់ក្នុងការចូលទៅកាន់ទីផ្សារពិភពលោក។ ប្រទេសកម្ពុជាកំពុងខាតបង់នូវតំលៃយ៉ាងច្រើននូវផលនេសាទសមុទ្រ បណ្តាលមកពីការផ្ទេរត្រី និងបង្គាទៅកាន់នាវាបរទេសដោយផ្ទាល់។ ប៉ុន្តែការចំណាយក្នុងការដឹកជញ្ជូន និងផ្ទុកទំនិញនៅកម្ពុជា មានក៏រិតខ្ពស់ជាខ្លាំងដែលពិបាកឱ្យពាណិជ្ជកម្មស្របច្បាប់អាចបានទទួលផលចំណេញ។

**៣. ផលិតផលសូត្រ**

តម្រូវការសូត្រ និងផលិតផលសូត្រសំរាប់ទីផ្សារពិភពលោកមានបរិមាណតិច ប៉ុន្តែមានតំលៃខ្ពស់។ ផលិតកម្មសរសៃសូត្រមានចំណែកតិចជាង 0.២% នៃទីផ្សារសរសៃវាយនភណ្ឌពិភពលោក។ ថ្លៃសូត្រនៅខ្ពស់ជាងថ្លៃកប្បាសនៅ ២០ ដង។ សូត្រនៅរបស់កម្ពុជាមានគុណភាពខ្ពស់ តែការផលិតមានចំនួនតិចណាស់។ បច្ចុប្បន្ន ប្រទេសកម្ពុជាមានសមត្ថភាពតិចតួចណាស់ក្នុងកិច្ចដំនើរការតាមបែបសេដ្ឋកិច្ចខ្នាតធំ។ វិធាន WTO មានឥទ្ធិពលតិចតួចប៉ុណ្ណោះមកលើផលិតផលសូត្រ។

**ជ. សង្ហារឹមដែលធ្វើអំពី ស្បៀ និង ផ្តៅ**

បច្ចុប្បន្ននេះ ផលិតកម្មគ្រឿងសង្ហារឹមរបស់កម្ពុជាពុំបានរៀបចំ សំរាប់នាំចេញឡើយ។ ទោះជាកម្ពុជាមានវត្ថុធាតុដើម និងមានអ្នកជំនាញក្តី ក៏គេផលិតគ្រឿងសង្ហារឹមសំរាប់លក់បំរើឱ្យតែសេចក្តី ត្រូវការនៅក្នុងទីផ្សារក្នុងប្រទេសប៉ុណ្ណោះ។ នៅក្នុងពេលនេះ ប្រទេសកម្ពុជា ពុំមានការរៀបចំផលិតករ សមស្របហើយក៏គ្មានហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តសមស្របសំរាប់ធ្វើពាណិជ្ជកម្មខ្នាតធំឡើយ ។ ប្រការនេះអាចតំរូវឱ្យមានការចូលរួមពីដៃគូបរទេស។

**ឋ. សំលៀកបំពាក់**

ក្នុងឋានៈជាវិស័យនាំចេញចំបងរបស់កម្ពុជា វិស័យសំលៀកបំពាក់ពឹងផ្អែកយ៉ាងខ្លាំងលើការអភិវឌ្ឍន៍ពេលអនាគតនៅក្នុង WTO។ លក្ខខ័ណ្ឌពិសេសអនុវត្តចំពោះវិស័យវាយនភណ្ឌ និងវិស័យកាត់ដេរក្នុងពិភពលោកសំរាប់រយៈពេល ៤០ ឆ្នាំ បានបញ្ចប់នៅក្នុងខែ មករា ឆ្នាំ ២០០៥ ដោយគ្មានការធានាក្នុងការផ្តល់កូតានាំចូលទៅកាន់ទីផ្សារសហរដ្ឋអាមេរិក។ គេបារម្ភថា ប្រទេសកម្ពុជាក៏ដូចជា ប្រទេសដទៃទៀតនឹងត្រូវលុបបំបាត់ដោយប្រទេសចិនដែលមានថ្លៃចំណាយផលិតកម្មទាប។ ប្រទេសកម្ពុជាមានឧត្តមភាពមួយចំនួន ព្រោះថាកម្ពុជាមានសាវតាល្អស្តីពីសិទ្ធិការងារ និងអាចមានលទ្ធភាពនាំចូលទៅកាន់សហភាពអឺរ៉ុបដោយរួចពន្ធ។ ប្រការនេះមានន័យថា កម្ពុជាត្រូវបង្កើតឱ្យមានវិស័យវាយនភណ្ឌនៅក្នុងប្រទេស ឬវិវឌ្ឍវិធីសាស្រ្តនៃការផលិតសំលៀកបំពាក់ តាមរយៈកិច្ចសហការជាមួយដៃគូរពីបណ្តាប្រទេសអាស៊ាន។

**ឌ.សេវាហិរញ្ញវត្ថុ**

កង្វះលទ្ធភាពក្នុងការទទួលសេវា សេវាហិរញ្ញវត្ថុ ដែលមានលក្ខណប្រកួតប្រជែង គឺជាឧបសគ្គរចនាសម្ព័ន្ធចំពោះការអភិវឌ្ឍ និងការវិនិយោគដែលផ្តោតលើពាណិជ្ជកម្មនៅកម្ពុជា។ នៅក្នុងរយៈពេលវែង ប្រសិនបើកម្ពុជាធ្វើកំនែទំរង់នានា ដែលបណ្តាលឱ្យមានការផ្លាស់ប្តូរកិច្ចប្រតិបត្តិអាជីវកម្ម និងឥរិយាបទថសាធារណៈចំពោះឥណទាននោះអាចនឹង ទាក់ទាញក្រុមហ៊ុន សេវាហិរញ្ញវត្ថុបរទេស ឱ្យចូលមកវិនិយោគ និងបង្កើនសេវានានារបស់ធនាគារនិងក្រុមហ៊ុនធានារ៉ាប់រងបច្ចុប្បន្ន។

**ឍ.សេវាសំណង់ និង សេវាពាក់ព័ន្ធ**

ដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសំរាប់ឱ្យមានការអភិវឌ្ឍ ដែលផ្តោតលើការនាំចេញ ប្រទេសកម្ពុជាក៏ត្រូវការវិស័យសំណង់ ដែលមានលទ្ធភាពក្នុងការផ្តល់សេវាទំនើបមានប្រសិទ្ធភាព និងមានភាពប្រគួតប្រជែង និងមួយចំនួនគ្រប់គ្រងដោយបរទេស។ ដើម្បីឱ្យមានលក្ខណប្រគួតប្រជែងក្រុមហ៊ុនវិស្វកម្ម និងក្រុមហ៊ុនស្ថាបត្យកម្ម។ ការសន្យាអំពីផ្នែកសេវារបស់កម្ពុជាចំពោះ អនុញ្ញាតឱ្យមាន ការបើកទូលាយជាបង្គួរ ចំពោះក្រុមហ៊ុនបរទេស។ ប៉ុន្តែក្រុមហ៊ុនសំណង់ចាំបាច់ត្រូវធានាសម្ភារៈ បរិក្ខារទៅ តាមលក្ខខណ្ឌដែលមានលក្ខណអំណោយផលបំផុត។

# សេចក្តីសន្និដ្ឋាន

ចាប់តាំងពីឆ្នាំ ១៩៩៩ រដ្ឋាភិបាលកម្ពុជាអាណត្តិទី២ បានសន្យាថា នឹងធ្វើអោយព្រះរាជាណាចក្រកម្ពុជាក្លាយទៅជាសមាជិកមួយរបស់អង្គការពាណិជ្ជកម្មពិភពលោក WTO ។ ចំណែកឯរដ្ឋសភាវិញក៏បានខិតខំប្រឹងប្រែងផងដែរក្នុងការតាក់តែងច្បាប់ជាង ៤0 តំរូវអោយសមស្របតាមប្រព័ន្ធគតិយុត្តរបស់អង្គការពាណិជ្ជកម្មពិភពលោក WTO ហើយរដ្ឋាភិបាលកម្ពុជា ក៏បានជុំរុញអោយមានសន្ទុះចរចារទ្វេភាគី និងពហុភាគីបន្ថែមទៀតជាមួយបណ្តាប្រទេសជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក WTO ។

ក្នុងការចរចារទ្វេភាគីជាមួយសហគមន៍អឺរ៉ុប (EU) កម្ពុជាបានត្រូវអនុញ្ញាតអោយមាន ការនាំចូលទំនិញវាយ ភ័ណ្ឌដូចជា សំលៀកបំពាក់ជាដើម ចូលក្នុងទីផ្សារអឺរ៉ុប ហើយត្រូវបានបង្កើនល្បឿនចាប់តាំងពីឆ្នាំ ២00៣ មកម្ល៉េះ។ ចំពោះប្រទេសចិន ក៏ដូចជាសហគមន៍អឺរ៉ុប បានព្រមអោយកម្ពុជានាំចូលនូវទំនេញផ្សេងៗដែរ។ ចំណែកឯការនាំចេញ ទំនិញកម្ពុជាទៅក្នុងសហរដ្ឋអាមេរិចវិញ ពុំទាន់ទាន់មានភាពល្អប្រសើរនៅឡើយទេ ព្រោះការនាំទំនិញចូលនូវមាន ក៏រិតដោយសារតែទីផ្សារនៅសហរដ្ឋអាមេរិចមានការប្រកួតប្រជែង។

ចំពោះកិច្ចប្រជុំពហុភាគី កាលពីថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ២00៣ ដែលដឹកនាំដោយឯកឧត្ត ចម ប្រសិទ្ធ រដ្ឋមន្រ្តីក្រសួងពាណិជ្ជកម្ម ឯកឧត្តម សុក ស៊ីផាន់ណា រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម និងក្រុមការងារបានធ្វើការចរចារនៅទីក្រុង ហ្សឺណែវ ប្រទេស ស្វីស យើងឃើញថា ការចរចារនេះទទួលបានជាផ្លែផ្កាប្រកបដោយជោកជ័យ ហើយ ប្រទេសជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក WTO ស្នើរសុំអោយមានការបង្កើតអាស័យដ្ឋានអ៊ិនធ័រណែត (Web Site) ទាក់ទងច្បាប់វិនិយោគទុន ដើម្បីអោយវិនិយោគទុនដឹងច្បាស់ងាយស្រួលធ្វើការទំនាក់ទំនងបណ្តាក់ទុន នៅព្រះរាជាណាចក្រកម្ពុជា។

សរុបសេចក្តីមក ដើម្បីអោយក្លាយទៅជាផ្នែកមួយនៃពាណិជ្ជកម្មដ៏ធំធេងកម្ពុជាត្រូវតែ ចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក WTO និងធ្វើការប្រកួតប្រជែងអោយបានគ្រប់គ្រាន់ សំរាប់បំរើសេចក្តីត្រូវការ និងផ្តល់ពតិមានដល់អ្នកទិញ ព្រមទាំងទាក់ទាញការវិនិយោគទុន អោយកាន់តែច្រើន ដើម្បីលើកស្ទួយសេដ្ឋកិច្ចជាតិអោយមានការរីកចំរើន។

# មាតិកា


សេចក្ដីផ្ដើម........................................................1

ផ្នែកទី១ អង្គការពាណិជ្ជកម្មពិភពលោក WTO........................2

I. ប្រវត្តិសង្ខេបរបស់ WTO ..........................................2

ក. និយមន័យ WTO ..................................................2

ខ. ប្រវត្តិសង្ខេបរបស់ WTO ..........................................2

II. គោលបំណង និង មុខងាររបស់ WTO ..................................4

ក. គោលការណ៍ និងគោលបំណង.........................................4

១. គោលការណ៍ .......................................................4

២. គោលបំណងរបស់ WTO ..............................................7

ខ. មុខងារ..............................................................7

III. រចនាសម្ព័ន្ធអង្គការពាណិជ្ជកម្មពិភពលោក ............................8

ក. សន្និសិទ្ធថ្នាក់រដ្ឋមន្ត្រី ..............................................8

ខ. អគ្គក្រុមប្រឹក្សា.......................................................8

គ. ក្រុមប្រឹក្សាពាណិជ្ជកម្មលើទំនិញ........................................8

ឃ. ក្រុមប្រឹក្សាពាណិជ្ជកម្មលើសេវាកម្ម .....................................8

ង. ក្រុមប្រឹក្សាផ្នែកកម្មសិទ្ធបញ្ញា ..........................................9

ច. អង្គភាពដោះស្រាយវិវាទ.................................................9

ឆ. លេខាធិការដ្ឋាន WTO................................................11

ជ. សមាជិកភាព .........................................................11

IV. លក្ខណៈសម្បត្តិដើម្បីក្លាយទៅជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក WTO ...11

ក.បេក្ខភាព.............................................................11

ខ.ការស្មើភាព..........................................................12

គ.ការបង្ហាញជំនួយការផ្នែកស្មារតី ស្ដីពីរបបពាណិជ្ជកម្មក្រៅប្រទេស ..............12

ឃ.លក្ខខ័ណ្ឌនៃការចូលជាសមាជិក ...........................................12

ង.ការចរចារទ្វេភាគី.......................................12
ច.ការយល់ព្រមតាមលក្ខខ័ណ្ឌនៃការចូលជាសមាជិកភាពដោយមានលក្ខខ័ណ្ឌ.......12
ឆ.សមាជិកភាព.......................................13
ផ្នែកទី២ កម្ពុជាក្នុងអង្គការពាណិជ្ជកម្មពិភពលោក.......13
I. លក្ខសម្បត្តិរបស់កម្ពុជាក្នុងការចូលជាសមាជិក.......13
ក.ការកសាងគំរោងការងារច្បាប់.......................14
ខ.ការសិក្សាលើការអនុវត្តសុំចូលជាសមាជិក WTO.......14
គ.ការកំនត់អាទិភាពសំរាប់កំណែទំរង់ច្បាប់មុនចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក WTO..14
ឃ.ដំណាក់កាលអន្តរកម្មរបស់កម្ពុជាក្នុងសមាជិកភាព WTO.......15
II. គុណសម្បត្តិ និងគុណវិបត្តិ.......................18
ក. គុណសម្បត្តិ.......................................18
១. ការពង្រីកទីផ្សារសំរាប់ផលិតផលកម្ពុជា.......19
២. ផលប្រយោជន៍ចំពោះឧស្សាហកម្មវាយនភ័ណ្ឌ និងសំលៀកបំពាក់.......19
៣. ការទាក់ទាញវិនិយោគទុនបរទេស.......20
៤. ការទទួលសិទ្ធិស្មើគ្នាក្នុងការចរចារ និងដោះស្រាយជំលោះពាណិជ្ជកម្ម.......20
៥. ការទទួលបានទូវជំនួយបរទេស.......20
ខ. គុណវិបត្តិ.......................................21
១. ផលប៉ះពាល់នៃតារាងពន្ធគយ.......21
២. បញ្ហាប្រកួតប្រជែងផលិតផលក្នុងស្រុកលើទីផ្សារអន្តរជាតិ.......23
III. ផលិតផលកម្ពុជានាំចេញ.......................25
ក.កសិកម្មអាជីវកម្មទូទៅ.......................25
ខ. អង្ករ.......................................25
គ. គ្រាប់ស្វាយចន្ទី.......................................26
ឃ. បសុសត្វ.......................................26
ង.ផ្លែស្វាយ.......................................26
ច.ប្រេងរុក្ខជាតិ.......................................26

ឆ. ស្រាទឹកត្នោត ........................................ 27

ជ. កៅស៊ូ ........................................ 27

ឈ. ត្រី........................................ 27

ញ. ផលិតផលសូត្រ ........................................ 28

ឋ. សំលៀកបំពាក់........................................ 28

ឱ.សេវាហិរញ្ញវត្ថុ........................................ 28

ឍ.សេវាសំណង់ និង សេវាពាក់ព័ន្ធ ........................................ 28

សេចក្តីសន្និដ្ឋាន ........................................ 30

ឧបសម្ព័ន្ធ ........................................ 35

## ឯកសារយោង

- កម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក
- ព្រឹត្តិប័ត្រស្រាវជ្រាវពាណិជ្ជកម្ម ឆ្នាំទី ១ លេខ ១ ខែ វិច្ឆិកា ឆ្នាំ ២០០១
- ព្រឹត្តិប័ត្រស្រាវជ្រាវពាណិជ្ជកម្ម ឆ្នាំទី ២ លេខ ២ ខែ វិច្ឆិកា-ធ្នូ ឆ្នាំ ២០០១
- ព្រឹត្តិប័ត្រស្រាវជ្រាវពាណិជ្ជកម្ម ឆ្នាំទី ៣ លេខ ១ ខែ តុលា ឆ្នាំ ២០០២
- ព្រឹត្តិប័ត្រស្រាវជ្រាវពាណិជ្ជកម្ម ឆ្នាំទី ៣ លេខ ១ ខែ មករា-កុម្ភៈ ឆ្នាំ ២០០៣
- WWW.wto.org

# ឧបសម្ព័ន្ធ